ការបោះពុម្ពផ្សាយ

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

Vol. 03



## ការវិវត្តនៃលទ្ធិប្រជាធិបតេយ្យ

# យុត្តិធម៌សង្គមតាមទស្សនវិស័យរបស់សហគមន៍សាសនាទាំងឡាយ

រៀបរៀងដោយ:

ឯកឧត្តម ភីតធ័រ ស៊ែស

ព្រះទេពសត្ថា ឃី សុវណ្ណរតនា

ឯកឧត្តម អ៊ុំ ទី

លោកបូជាចារ្យ យ៉ូហាន អ៊ិន សុន

ឯកឧត្តម វ៉ាន់ ម៉ាត់

ធ្នូ
២០០៧

Konrad Adenauer Stiftung

ការបោះពុម្ពផ្សាយ

Vol. 03

karvvtén I T
RbCaFbetyü

# ytFmsgmtamTsSnvsy rbsshKmnsasnaTagLay

រៀបរៀងដោយ

ឯកឧត្តម គីតឆាំរ ទៃស

ព្រះទេពសត្ថា ឃី សុវណ្ណរតនា

ឯកឧត្តម អ៊ុង ឆី

លោកបូជាចារ្យ យ៉ូហាន អ៊ុន សុន

ឯកឧត្តម ទ៉ាន់ ម៉ាត់


បោះពុម្ពដោយ

Konrad Adenauer Stiftung

មូលនិធិ ខុនរាដ អាដិនណៅអ៊ែរ

ព្រះរាជាណាចក្រកម្ពុជា

## អំពីមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ គឺជាមូលនិធិនយោបាយមួយរបស់ប្រទេសអាល្លឺម៉ង់ ហើយឈ្មោះរបស់មូលនិធិ គឺជាឈ្មោះរបស់លោកអធិការបតីដំបូង នៃប្រទេសអាល្លឺម៉ង់ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ផ្តល់ជូននូវការប្រឹក្សា ការបណ្តុះបណ្តាល ស្តីពីអភិបាលកិច្ចល្អជាមួយនឹងទស្សនវិស័យជំរុញឱ្យមានស្ថាប័ននយោបាយប្រជាធិបតេយ្យ និងគោលនយោបាយផ្សេងៗ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ធ្វើសកម្មភាពនៅក្នុង១២០ប្រទេសទូទាំងពិភពលោក។ ពាក់កណ្តាលនៃសកម្មភាពទាំងអស់របស់មូលនិធិ ត្រូវបានធ្វើយ៉ាងខ្ជាប់ខ្ជួននៅក្នុងប្រទេសអាល្លឺម៉ង់។ ការិយាល័យនៅប្រទេសកម្ពុជាបានបង្កើតឡើងនៅឆ្នាំ១៩៩៤។ ដៃគូរបស់មូលនិធិរួមមាន រដ្ឋសភា ព្រឹទ្ធសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងជំនាញមួយចំនួន គណបក្សនយោបាយដែលមានអសនៈក្នុងរដ្ឋសភា ប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិលដទៃទៀត។ ក្នុងឆ្នាំថ្មីៗកន្លងទៅនេះ មូលនិធិ បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់គាំទ្រដល់វិមជ្ឈការប្រជាធិបតេយ្យ។

## ការបោះពុម្ពផ្សាយស្តីពីការវិវត្តនៃលទ្ធិប្រជាធិបតេយ្យ

នៅក្នុងការផ្សាយលើកនេះ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ បានចងក្រងឯកសារដែលពាក់ព័ន្ធ ផ្តល់ឱ្យពីកិច្ចសហប្រតិបត្តិការជាមួយដៃគូនៅកម្ពុជាតាមកម្មវិធីការងារជំនាញនីមួយៗ។

© រក្សាសិទ្ធិ ២០០៧ ដោយមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ, ព្រះរាជាណាចក្រកម្ពុជា

**រៀបរៀងដោយ:**
ឯកឧត្តម **គីតឆ័រ ថៃស**, ព្រះទេពសត្ថា **ឃី សុវណ្ណរតនា**, ឯកឧត្តម **អ៊ុច ធី**,
លោកបូជាចារ្យ យ៉ូហាន **អ៊ិន សុន**, ឯកឧត្តម **វ៉ាន់ ម៉ាត់**

**បោះពុម្ពដោយ:**
មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ
ផ្ទះលេខ៤, ផ្លូវលេខ៤៦២,
ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ៩៤៤
ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥-២៣) ២១៣ ៣៦៣, ៧២៦ ២២១
ទូរសារ : (៨៥៥-២៣) ២១៣ ៣៦៤
អ៊ីមែល : office@kas-cambodia.com
គេហទំព័រ : www.kas.de/kambodscha

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

ISBN-13: 978-99950-880-5-7

# កថាមុខ

ព្រឹត្តិប័ត្រស្តីអំពីការវិវត្តនៃលទ្ធិប្រជាធិបតេយ្យ ដែលបោះពុម្ពផ្សាយដោយ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរលើកនេះ នឹងផ្តោតទៅលើពាក្យថា "យុត្តិធម៌សង្គម" តាមទស្សនៈជំនឿរបស់ពុទ្ធសាសនា គ្រិស្តសាសនា និងឥស្លាមសាសនា។

យើងបានសុំឱ្យក្រុមសាសនិកដែលល្បីល្បាញទាំងឡាយក្នុងពុទ្ធសាសនា គ្រិស្តសាសនានិកាយប្រូតេស្តង់ និងកាតូលិក និងឥស្លាមសាសនា នៅក្នុងប្រទេសកម្ពុជា ជួយវែកញែកលើពាក្យថា "យុត្តិធម៌សង្គម"។ ក្នុងនេះផងដែរ យើងក៏បានសុំឱ្យសមាជិកសភាអាល្លឺម៉ង់កាន់គ្រិស្តសាសនានិកាយកាតូលិកម្នាក់ ជួយបន្ថែមទស្សនៈរបស់គាត់តាមបែបអឺរ៉ុបផងដែរ។

អាណត្តិរបស់មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ គឺការលើកកំពស់ស្ថាប័ន និងគោល-ការណ៍នយោបាយប្រជាធិបតេយ្យទេ ក៏ប៉ុន្តែតើហេតុអ្វីបានជាយើងលើកឡើងនូវទស្សនទាន "យុត្តិធម៌សង្គម" មួយនេះ តាមទស្សនៈសាសនាទាំងឡាយ ជាជាងការលើកឡើងតាមទស្សនៈនយោបាយទៅវិញ? ចំលើយចំពោះរឿងនេះ គឺងាយស្រួលទេ!

ជាការពិតប្រាកដណាស់ ដែលថាយើងគ្មានបំណងជ្រៀតជ្រែកទៅក្នុងកិច្ចការរបស់សហគមន៍សាសនាណាមួយនៅក្នុងប្រទេសកម្ពុជាឡើយ។ ហើយនៅក្នុងសៀវភៅនេះ ក៏យើងគ្មានបំណងព្យាយាម ដើម្បីវែកញែកទៅលើបញ្ហាទំនាក់ទំនងជារវាងរដ្ឋ នឹងអង្គការសាសនានានាដែរ។ ក្រុមសាសនា និងរដ្ឋ ទាក់ទងគ្នាតាមរយៈស្ថាប័នដែលមានលក្ខណៈ ឯករាជភាពពីគ្នាទៅវិញទៅមក។

ក្នុងសៀវភៅនេះ យើងនិយាយអំពីចំណងទាក់ទងរវាងសាសនា នឹងនយោបាយ។ ចំណងទាក់ទងនេះ ក៏កំណត់នូវបណ្តុំបញ្ហាមួយចំនួនទៀតផងដែរ។ សាសនានិងនយោបាយគឺជារឿងដែលទាក់ទងជាមួយនឹងសកម្មភាពមុខពីរ នៅក្នុងជីវិតរបស់មនុស្សតែមួយ ព្រោះថាពលរដ្ឋដែលស្ថិតនៅក្នុងក្រុមនៃសាសនាទាំងឡាយ ក៏ជាសមាជិកនៃសង្គមអាណាចក្រមួយដែរ។ ការចូលរួមជាទ្វេមុខនេះ បានបង្កើតអោយមានទំនាក់ទំនងដ៏ជិតស្និតមួយរវាងសាសន-ចក្រ និងអាណាចក្រ។ តាមរយៈទំនាក់ទំនងនេះ យើងមានបំណងនឹងសម្លឹងមើលថាៈ តើជំនឿសាសនាបានជ្រៀតចូលទៅក្នុងជំរើសនយោបាយ និងការធ្វើសេចក្តីសំរេចចិត្តរបស់អាណា-

ចក្រយ៉ាងណាដែរ។

ជំនឿសាសនាតែងមានផលវិបាកខាងផ្នែកសីលធម៌ សង្គម និងនយោបាយ។ វាជាការសមស្របសំរាប់សាសនិកទាំងនោះ ដើម្បីបញ្ជាក់នូវផលវិបាកទាំងនេះតាមរយៈសកម្មភាពទាំងឡាយក្នុងឋានៈពួកគេជាពលរដ្ឋនៅក្នុងសណ្តាប់ធ្នាប់ខាងផ្នែកនយោបាយ។ ជំនឿសាសនាធ្វើឱ្យអាណាចក្រនយោបាយមានសុពលភាព។ ជំនឿទាំងនោះ ត្រូវបានត្រិះគិតឡើងដោយសាវ័កដែលជាអ្នកគាំទ្រជាច្រើន ដែលជាអ្នកមានអំណាចដ៏ខ្ពង់ខ្ពស់ក្នុងសាសនា។ អ្នកនយោ-បាយ និងរដ្ឋត្រូវបានគេណែនាំអោយរៀបចំគោលនយោបាយ ឱ្យបានសមស្របទៅនឹងជំនឿទាំងនេះ។

គំនិតស្តីពីយុត្តិធម៌សង្គម គឺឧត្តុងឧត្តមណាស់នៅក្នុងគោលនយោបាយរបស់រដ្ឋមួយ។ ក្នុងដំណើរការរីកចំរើនដ៏ឆាប់រហ័សផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា (ក៏ដូចជានៅក្នុងប្រ-ទេសដទៃទៀតដែរ) គម្លាតរវាង អ្នកមាននិងអ្នកក្រ គឺនៅឆ្ងាយដាច់ពីគ្នានៅឡើយ។ ក្នុងកំរិតណាមួយនោះ និន្នាការនេះនឹងទាមទារអោយមានសិទ្ធិនៅក្នុងគោលនយោបាយរដ្ឋជាមិនខាន។ ទៅតាមន័យបែបនេះ អត្ថបទដែលបង្ហាញក្នុងសៀវភៅនេះ នឹងមានលក្ខណៈជានយោបាយដោយធម្មជាតិ។

ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះបណ្ណាធិការទាំងអស់ ដែលបានចូលរួមនៅក្នុងការងារធ្វើព្រឹត្តិប័ត្រនេះ ដែលរួមមានៈ

- លោក **ហេង មណីចិន្តា** នាយកអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ដែលសមនឹងទទួលនូវការដឹងគុណជាពិសេស ចំពោះការពិនិត្យផ្ទៀងផ្ទាត់សៀវភៅនេះ ព្រមទាំងបានយកចិត្តទុកដាក់ក្នុងការបកប្រែពាក្យពេចន៍ និងទស្សនៈនានាដែលពិបាកៗក្នុងសាសនាបានយ៉ាងសមរម្យ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ មានកិត្តិយសណាស់ដែលបានធ្វើការជាមួយ លោក **ហេង មណីចិន្តា** ក្នុងពេលជាងពីរទសវត្សកន្លងមកនេះ។ យើងតែងបានព្រមព្រៀងគ្នាក្នុងការវាយតម្លៃថា គុណតម្លៃខាងចរិយាធម៌ សីលធម៌ និងសាសនា មានសារៈសំខាន់ណាស់សំរាប់វិស័យសេដ្ឋកិច្ច និងការធ្វើសេចក្តីសំរេចចិត្តផ្នែកនយោបាយ។

- លោក **យី ឆន់** អគ្គលេខាធិការក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា ដែលបានជួយដ៏សកម្មក្នុងការរៀបចំសិក្ខាសាលានៅទីក្រុងភ្នំពេញ នាខែសីហា ឆ្នាំ២០០៧ កន្លងមកនេះ និងបានជួយរៀបចំចងក្រង ព្រៀង និងពិភាក្សានូវឯកសារនេះមុននឹងចេញជាផ្លូវការ។

លោក **ទ័លហ្គាំង ម៉ៃយ៉េរ**

តំណាងប្រចាំប្រទេសកម្ពុជា

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

# សង្គមមានយុត្តិធម៌ និងយុត្តិធម៌សំរាប់សង្គម បរិការណ៍កម្ពុជា

បញ្ហាសង្គម និងសង្គមដែលមានបញ្ហា ជាបរិបទនៃការពិភាក្សា ការដេញដោល ការស្រាវជ្រាវ និងការឧទ្ទេសរបស់មហាជន និងបញ្ញវ័ន្ត តាំងពីមនុស្សចាប់ផ្តើមកើតនៅលើផែនដីមកម្លេះ[១]។ រហូតមកដល់ សតវត្សទី២១នេះហើយក្តី ក៏បរិបទនេះនៅតែជាចំណុចនៃការសិក្សាដ៏ទូលំទូលាយទូទាំងពិភពលោក។ សំរាប់ខ្មែរយើង បរិបទនេះមានទាំងនៅក្នុងប្រវត្តិសាស្ត្រតាំងពីបូរាណ និងប្រវត្តិសាស្ត្រទំនើប ហើយបច្ចុប្បន្ននេះ ក៏ជាបរិបទដែលនៅតែមានតំលៃដដែល។ ក្នុងទស្សនៈព្រះពុទ្ធសាសនា បញ្ហាសង្គម និងសង្គមដែលមានបញ្ហា នឹងនៅតែមានតទៅអនាគតកាលជានិច្ច ហើយការស្វែងរកវិធីដើម្បីដោះស្រាយបញ្ហាសង្គម (យុត្តិធម៌សំរាប់សង្គម) និងសេចក្តីសង្ឃឹមថានឹងមានសង្គមដែលគ្មានបញ្ហាមួយ (សង្គមមានយុត្តិធម៌) និងនៅតែជាបរិការណ៍របស់មនុស្សជាតិទាំងអស់ជានិច្ច។[២]

អត្ថបទទាំងឡាយដែលបានរួមរួបនៅក្នុងសៀវភៅនេះ បានបង្ហាញអោយឃើញថា យុត្តិធម៌ជាចំណុចរួម នៃការស្វែងរកសំរាប់គ្រប់សាសនាទាំងអស់ ដែលនៅក្នុងទីនេះមានពុទ្ធសាសនា ឥស្លាមសាសនា និងគ្រិស្តសាសនា។ សាសនានីមួយៗបានបង្ហាញនូវការយកចិត្តទុកដាក់របស់អ្នកបង្កើតសាសនា ក៏ដូចជាសាវ័កជំនាន់ក្រោយ ដែលព្យាយាមរួមចំណែកក្នុងការធ្វើអោយសង្គមមួយមានយុត្តិធម៌ ឬក៏បង្ហាញគោលការណ៍ផ្សេងៗដែលមាន "លក្ខណៈយុត្តិធម៌"សំរាប់សង្គមនីមួយៗ។

នៅកម្ពុជានាបច្ចុប្បន្ន ភាពយុត្តិធម៌ ឬមិនយុត្តិធម៌ក្នុងសង្គម ជាលទ្ធផលនៃការចាត់ចែងរៀបចំសង្គម របស់មេដឹកនាំខ្មែរ ជាផលិតផលរបស់ខ្មែរគ្រប់រូបដែលបានចូលរួម ឬមិនបានចូលរួមក្នុងការផលិតសង្គមនេះ និងជាផលដែលកើតឡើងពីការប៉ះទង្គិចនៃភូមិសាស្ត្រនយោបាយដែលគ្របដណ្តប់មកលើកម្ពុជា។ ការរំលោភសិទ្ធិមនុស្ស សិទ្ធិនយោបាយ សិទ្ធិស្ត្រី

[១] អគ្គញ្ញសូត្រ ទីឃនិកាយ បាដិកវគ្គ ព្រះត្រៃបិដកខ្មែរ

[២] ន័យក្នុងអរិយសច្ចៈ៤ ប្រការ

សិទ្ធិកុមារ និងសិទ្ធិដទៃទៀត ជាទិដ្ឋភាពមួយនៃសង្គមមិនមានយុត្តិធម៌។ កំរិតជីវភាព និងប្រាក់ចំណូលដែលខុសឆ្ងាយពីគ្នាពេក ធ្វើអោយមានអ្នកក្រខ្លាំង និងអ្នកមានខ្លាំង ក៏ជាទិដ្ឋភាពនៃអយុត្តិធម៌ផងដែរ។ អំពើពុករលួយ និងអាជីវកម្មមិនស្របច្បាប់នានា ក៏ជាទិដ្ឋភាពមួយទៀត។ ជាភាសាច្បាប់ នីតិរដ្ឋដែលមិនគ្រប់គ្រាន់ អាចជាទិដ្ឋភាពរួមនៃអយុត្តិធម៌សង្គម។ សង្គមកម្ពុជាយើងឥឡូវនេះ មានទិដ្ឋភាពទាំងអស់នេះជាអង្គប្រកប អង្គខ្លះក៏មានតិច អង្គខ្លះក៏មានច្រើន ដែលធ្វើអោយសង្គមយើងអាចនឹងត្រូវគេហៅថា ជាសង្គមមិនមានយុត្តិធម៌ល្អ។

ទោះជាយ៉ាងណាក្តី ពួកយើងមិនមែនជាអ្នករស់នៅក្នុងអតីតកាលទេ តែអតីតកាលជាមេរៀនដ៏ល្អសំរាប់យើង ព្រោះអតីតកាលអាចអោយយើងរៀបចំខ្លួន ដើម្បីបង្កើនយុត្តិធម៌ក្នុងសង្គមរបស់យើងនាបច្ចុប្បន្ន និងអនាគតបាន។ យើងមានវិធីជាច្រើនដើម្បីជួយបង្កើនយុត្តិធម៌សំរាប់សង្គម ដែលនៅក្នុងនេះ វិធីបែបសាសនាក៏ជាវិធីមួយដែលគួរឱ្យយកចិត្តទុកដាក់ឱ្យបានល្អប្រសើរដែរ។

ទាំងនៅក្នុងពុទ្ធសាសនា ឥស្លាមសាសនា និងគ្រិស្តសាសនា យុត្តិធម៌ត្រូវបានមេដឹកនាំសាសនាទាំងនោះយកចិត្តទុកដាក់ខ្លាំងណាស់ ព្រោះនោះគឺជាបណ្តូលរបស់សាសនាទាំងឡាយ ដែលចេញមកអំពីទឹកចិត្តប្រកបដោយមេត្តា ករុណា និងបញ្ញារបស់លោកទាំងនោះ។ ការប្រៀនប្រដៅរបស់លោកចំពោះសាវ័កទាំងអស់ ដែលជាសមាជិកសង្គម គឺការធ្វើយ៉ាងណាអោយបរិស័ទទាំងនោះ មានមេត្តា ករុណា និងបញ្ញាដូចលោកដែរ ព្រោះសន្តានចិត្តទាំង៣ប្រការនេះ គឺសំរាប់អោយមនុស្សរស់នៅជាមួយគ្នា ស្រឡាញ់គ្នា ជួយគ្នាទៅវិញទៅមក និងប្រើប្រាស់បញ្ញាសំរាប់ការរីកចំរើន។ ទាំង៣ប្រការនេះគឺជាយុត្តិធម៌សំរាប់សង្គម ដើម្បីអោយសង្គមនោះមានយុត្តិធម៌។ ដូច្នេះយុត្តិធម៌ មានលក្ខណៈទាំងជាឧបករណ៍សំរាប់កសាងសង្គម និងជាគុណភាពរបស់សង្គមផងដែរ។

បញ្ហារបស់សង្គមកម្ពុជាដែលយើងបានពោលមកខាងលើ ក្នុងន័យសាសនា គឺជាបញ្ហាដែលសន្តានចិត្តរបស់យើងខ្វះ ឬប្រើប្រាស់មិនបានត្រឹមត្រូវនូវមេត្តា ករុណា និងបញ្ញានេះឯង។ ទាំងនេះ អាចជាលទ្ធផលនៃសង្គ្រាមដ៏យូរលង់ អាចជាឥទ្ធិពលនៃសកលភាវូបនីយកម្ម ឬអាចជាការដែលសាវ័ករបស់មេសាសនា មិនបានចម្លងគុណធម៌ទាំង៣នេះមកអោយបរិស័ទរបស់ខ្លួនបានដោយត្រឹមត្រូវ ឬក៏អាចជាជាយុគសម័យមួយ ដែលមនុស្សជាតិកំពុង

បដិសេធនូវគុណធម៌ទាំងនេះ។ ទោះបីជាមួយណាក៏ដោយ ក្នុងឋានៈជាសមាជិកសង្គមខ្មែរ ឬជាបរិស័ទនៃសាសនាណាមួយ យើងមិនអាចបណ្ដែតបណ្ដោយអោយអយុត្តិធម៌សង្គមគ្រប ដណ្ដប់លើកម្ពុជានេះតទៅអនាគត ដោយមិនចេះចប់នោះឡើយ។ ជាពិសេសអ្នកដឹកនាំសាសនាទាំងឡាយ គួរតែពួតដៃគ្នាពង្រឹងនូវគុណធម៌ទាំង៣នេះឡើងវិញ ជាជាងការមានមានះថាមានតែគុណធម៌របស់សាសនា អញទេទើបអាចបង្កើតនូវយុត្តិធម៌ក្នុងសង្គមកម្ពុជាបាន។ ការជជែកពិភាក្សាគ្នា និងការយល់ចិត្តគ្នាទៅវិញទៅមកដូចជានៅក្នុងសិក្ខាសាលា អន្តរសាសនាស្ដីអំពីយុត្តិធម៌សង្គមនេះ គឺជាការចាប់ផ្ដើមមួយដ៏ល្អ សំរាប់អនាគតប្រសើរមួយនៃសង្គមខ្មែរដែលមានយុត្តិធម៌។

ខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ដែលជានិច្ចជាកាលបានយកចិត្តទុកដាក់ខ្លាំងណាស់អំពើយុត្តិធម៌សង្គមនេះ ហើយសង្ឃឹមថាបន្ទាប់ពីសិក្ខាសាលាអំពីយុត្តិធម៌សង្គម ក្នុងចំណោមអ្នកដឹកនាំសាសនា ហើយសិក្ខាសាលាដែលស្ថិតនៅក្នុងចំណោមបញ្ញវ័ន្ត និងអ្នកនយោបាយនឹងត្រូវបានមូលនិធិយកចិត្តទុកដាក់ទៀត ជាពុំខានព្រោះអ្នកទាំងអ្នកដឹកនាំសាសនា បញ្ញវ័ន្ត និងអ្នកនយោបាយតែងតែជាត្រីកោណនៃស្ថេរភាពសង្គម ដែលមានយុត្តិធម៌ជារៀងរហូត។

ធម្មបណ្ឌិត **ហេង មណីចិន្តា**

នាយកអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

# ទស្សនកថាស្ដីពីយុត្តិធម៌សង្គម

១. ភាពយុត្តិធម៌មានន័យថាជាភាពត្រឹមត្រូវ ប៉ុន្តែមិនមែនស្ថិតក្នុងផ្លូវជ្រើសរើសដោយសេរីពេកទេ។ ផ្ទុយទៅវិញ វាមានន័យថាជាភាពត្រឹមត្រូវដាច់ខាត ដែលមានមូលដ្ឋាននៅក្នុងច្បាប់ និងប្រពៃណីដ៏ពិសិដ្ឋ (Sittengesetzes) ដែលអ្នកកាន់សាសនាគ្រិស្តជឿជាក់ថា ផ្អែកលើគតិបណ្ឌិត និងសន្តិភាពរបស់ព្រះ ហើយគោរពតាមវិធានដាច់ខាត ដែលជាវិធានខ្ពស់បំផុត និងគ្របដណ្ដប់លើវិធានទាំងអស់ផ្សេងទៀត។

២. តាមការយល់ដឹងរបស់អ្នកកាន់សាសនាគ្រិស្ត មនុស្សម្នាក់ដែលត្រឹមត្រូវ គឺមនុស្សដែលគោរពតាមឆន្ទៈដ៏ពិសិដ្ឋរបស់ព្រះ ក្នុងរាល់ការប្រតិបត្តិ និងការមិនប្រតិបត្តិរបស់ខ្លួន ហើយក៏គោរពតាមជាទូទៅនូវសេចក្ដីបង្គាប់ក្នុងទំនាមទំលាប់ប្រពៃណី (Sittengesetzes) ជាពិសេសនីតិច្បាប់នានា។ យើងបានបន់ស្រន់ឱ្យមនុស្សមានលក្ខណៈត្រឹមត្រូវ ដែលមានមនសិការគោរព និងអនុវត្តតាមច្បាប់ទំលាប់ ហើយដែលពិសេសបានបំពេញភារកិច្ចគតិយុត្តិរបស់ខ្លួនពេញលេញ និងទាន់ពេលវេលា ហើយមិនបានទាមទារនូវអ្វីដែលពុំមានឡើយ។

៣. ទ្រឹស្ដីសង្គមសាសនាគ្រិស្តកំណត់ថាយុត្តិធម៌សង្គមគឺអ្វីដែលមានក្នុងប្រយោជន៍សាធារណៈ។ អ្នកទាំងឡាយណា រំលោភបំពានប្រយោជន៍សាធារណៈ គឺជាអំពើបាបប្រឆាំងនឹងយុត្តិធម៌សង្គម។ យុត្តិធម៌សង្គម និងប្រយោជន៍សាធារណៈ គឺជាឈ្មោះពីរសំរាប់វត្ថុតែមួយដូចគ្នា។ រដ្ឋនិយមសេរីភាពពិតប្រាកដ គោរពតាមគោលការណ៍ដ៏សំខាន់គឺថា: "រាល់អំពើឯកជនទាំងអស់ដែលមិនត្រូវបានហាមប្រាមជាពិសេសទេនោះ ត្រូវបានអនុញ្ញាតឱ្យធ្វើបាន"។ រដ្ឋសង្គមមួយដែលបង្កើតឡើង ផ្អែកលើធម្មាធិបតេយ្យ គោរពតាមគោលការណ៍យុត្តិធម៌សង្គមគឺថា: រាល់អំពើទាំងអស់ ដែលបំរើដល់អំពើល្អសាធារណៈ ហើយដែលមានសីលធម៌ល្អត្រឹមត្រូវ គឺជាអំពើដ៏សំខាន់ (von Rechts wegen) តាមកំរិតបទដ្ឋានគតិយុត្ត។

៤. មូលដ្ឋានយុត្តិធម៌គឺជាសមភាព នៃមនុស្សគ្រប់រូបក្នុងភាពថ្លៃថ្នូរ ដែលព្រះបានប្រទានដល់ពួកគេ។ យុត្តិធម៌ទាមទារឱ្យមានការប្រតិបត្តិរកគ្នាទៅវិញទៅមក ក្នុងលក្ខណៈស្មើភាពគ្នា។

នៅក្នុងរដ្ឋសង្គមមួយ ដែលបង្កើតឡើងផ្អែកលើធម្មាធិបតេយ្យ យុត្តិធម៌មានន័យថាជាសិទ្ធិដូចគ្នាពិតប្រាកដសំរាប់មនុស្សគ្រប់រូប។ ច្បាប់ការពារមិនឱ្យមានការប្រើប្រាស់ និងការរំលោភអំណាចដោយបំពាន។ ហើយច្បាប់ក៏ការពារសេរីភាពសំរាប់មនុស្សទន់ខ្សោយផងដែរ។

៥. យុត្តិធម៌ទាមទារអោយមានឱកាសស្មើគ្នា សំរាប់មនុស្សគ្រប់រូប។ មនុស្សគ្រប់រូបគប្បីមានឱកាសដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់របស់ខ្លួនដោយសេរី។ ដូច្នេះហើយ ទើបមានការទាមទារឱ្យមានឱកាសដូចគ្នាក្នុងវិស័យអប់រំ និងក្នុងពិភពការងារ។

៦. យុត្តិធម៌មានអនុភាពធ្វើឱ្យសង្គមមានលក្ខណៈស្មើគ្នា និងទាមទារឱ្យមានការបែងចែកបន្ទុកស្មើគ្នាផងដែរ។ នេះជាហេតុផលដែលមានយុត្តិធម៌ នៅពេលអ្នកខ្លាំងបានរួមចំណែកវិភាគទានរបស់ខ្លួន ដល់សហគមន៍ច្រើនជាងអ្នកទន់ខ្សោយ។

៧. យុត្តិធម៌ធ្វើឱ្យមានសន្តិភាពពិតប្រាកដ។ នៅពេលណាដែលសិទ្ធិរបស់មនុស្សដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរ ត្រូវបានគេមិនគោរព ហើយនៅទីណាដែលសេរីភាពរបស់បុគ្គលម្នាក់ៗក្នុងក្រុមណាមួយ ឬក្នុងសង្គមមនុស្សទាំងមូលត្រូវបានគេកៀបសង្កត់នោះ អំពើហឹង្សា និងភាពចលាចលពិតជាកើតមានឡើង។ ការផ្តល់យុត្តិធម៌ និងសន្តិភាពមានន័យថាគោរពសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ហើយមានន័យថាយកឈ្នះលើទុក្ខវេទនា ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។

ឯកឧត្តម **ភីតធ័រ វៃស**
(Peter Weiss MdB)

# មាតិកា


**កថាមុខ** ........................................ ៥

**សង្គមមានយុត្តិធម៌ និងយុត្តិធម៌សំរាប់សង្គម បរិការណ៍កម្ពុជា** ........................................ ៩

**ទស្សនកថាស្តីពីយុត្តិធម៌សង្គម** ........................................ ១៣

**មាតិកា** ........................................ ១៥

**ការបញ្ចូលចំណាប់អារម្មណ៍ និងជំនឿរបស់ក្រុមសាសនាក្នុងឆាកនយោបាយ** ........ ១៩

១. ការវិវត្តប្រវត្តិសាស្ត្រ ........................................ ១៩

២. ទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋនាពេលបច្ចុប្បន្ន ........................................ ២១

៣. ឥទ្ធិពលរបស់ព្រះវិហារលើនយោបាយ ........................................ ២៣

៤. ទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋ ក្នុងទ្វីបអឺរ៉ុប ........................................ ២៤

៥. ព្រះវិហារ និងរដ្ឋ ក្នុងសេចក្តីព្រាងរដ្ឋធម្មនុញ្ញអឺរ៉ុប ........................................ ២៤

**យុត្តិធម៌សង្គមតាមទស្សនៈវិស័យព្រះពុទ្ធសាសនា** ........................................ ២៧

១. សេចក្តីផ្តើម ........................................ ២៧

២. មនុស្សមានសមធម៌ពីកំណើត ........................................ ២៨

៣. ព្រះពុទ្ធសាសនា និងសិទ្ធិមនុស្ស ........................................ ២៩

៤. សមភាព និងឧត្តមភាព ........................................ ៣០

៥. ឋានៈរបស់មនុស្ស ........................................ ៣១

៦. សិទ្ធិ និងសមភាព ........................................ ៣២

៧. មាគ៌ាបរិសុទ្ធ ........................................ ៣៣

៨. វិធីហ្វឹកហាត់៣យ៉ាង ........................................ ៣៤

៩. បញ្ញានិងសីល ........................................ ៣៥

១០. បញ្ញានិងករុណា ........................................ ៣៦

១១. ច្បាប់កម្មផល ........................................ ៣៦

១២. អសមភាព.......................................................................................................៣៧
១៣. សេរីភាពគំនិត...............................................................................................៣៨
១៤. សេរីភាពសាសនា.............................................................................................៣៩
១៥. ព្រហ្មវិហារធម៌.............................................................................................. ៤០
១៦. ជៀសវាងអគតិ............................................................................................... ៤១
១៧. សេចក្តីសន្និដ្ឋាន...........................................................................................៤២
**ទស្សនៈនៃយុត្តិធម៌របស់សហគមន៍គ្រិស្តបរិស័ទ គណៈនិកាយប្រូតេស្តង់កម្ពុជា**..... ៤៣
១. សេចក្តីផ្តើម.........................................................................................................៤៣
២. ការអប់រំសីលធម៌ចំពោះសង្គម............................................................................... ៤៤
៣. មូលដ្ឋាននៃអយុត្តិធម៌សង្គម..................................................................................... ៤៦
*ក. ប្រភពនៃយុត្តិធម៌សង្គម*.........................................................................................៤៧
*ខ. បញ្ហាកង្វះយុត្តិធម៌សង្គម*.......................................................................................៤៧
៤. ការអនុវត្តនូវទស្សនៈយុត្តិធម៌សង្គម ..................................................................... ៤៨
៥. បញ្ចាប់ និងសំណូមពរសំរាប់ការអនុវត្តនូវយុត្តធម៌សង្គម .........................................៥២
**ទស្សនៈនៃយុត្តិធម៌របស់សហគមន៍កាតូលិកកម្ពុជា** ......................................................... ៥៥
១. សេចក្តីផ្តើម.........................................................................................................៥៥
២. ទស្សនៈនៃយុត្តិធម៌សង្គម........................................................................................ ៥៦
៣. យុត្តិធម៌ជាអ្វី ?......................................................................................................... ៥៦
៤. ទស្សនៈនៃយុត្តិធម៌សង្គមតាមគ្រិស្តសាសនា.........................................................៥៧
៥. តើជំនឿសាសនារបស់យើង សង្ឃឹមថាអាចនឹងអនុវត្តទស្សនៈ នៃយុត្តិធម៌សង្គម
ក្នុងជីវិតប្រចាំថ្ងៃបានដែរឬទេ?.........................................................................៧១
៦. សេចក្តីបញ្ចប់.......................................................................................................៧៤
**យុត្តិធម៌សង្គមតាមទស្សនៈវិស័យឥស្លាមសាសនា**..........................................................៧៥
១. សេចក្តីផ្តើម.........................................................................................................៧៥

២. ការកំណត់របស់សាសនាឥស្លាម.......................................................................... ៧៥
៣. ឥស្លាម និងសិទ្ធិសេរីភាព......................................................................................... ៧៥
៤. ឥស្លាម និងការប្រឆាំងអំពើភេរវកម្ម........................................................................... ៧៦
៥. យុត្តិធម៌ក្នុងសង្គមសាសនាឥស្លាម............................................................................ ៧៦
**ជីវប្រវត្តិសង្ខេប** ................................................................................................ ៧៩
ឯកឧត្តម **គីតធំរ វៃស** សមាជិកសភានៃរដ្ឋសហព័ន្ធអាល្លឺម៉ង់.............................. ៧៩
លោក **ហេង មណីចិន្តា** នាយកអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍........................ ៨១
ព្រះទេពសត្ថា **ឃឹ សុវណ្ណរតនា** ព្រះរាជាគណៈចត្វា.......................................... ៨២
ឯកឧត្តម **អ៊ុំ ទី** តំណាងសហគមន៍គ្រិស្តបរិស័ទគណៈនិកាយប្រូតេស្តង់................. ៨៣
លោកបូជាចារ្យ **អ៊ុន សុន** តំណាងព្រះសហគមន៍កាតូលិកកម្ពុជា........................... ៨៤
ឯកឧត្តម **វ៉ាន់ ម៉ាត់** សមាជិកព្រឹទ្ធសភា, ប្រធានសមាគមឥស្លាមកម្ពុជា................ ៨៦

# ការបញ្ចូលចំណាប់អារម្មណ៍ និងជំនឿរបស់ក្រុមសាសនា ក្នុងឆាកនយោបាយ

ឯកឧត្តម ភីតធ័រ វៃស
សមាជិកសភានៃរដ្ឋសហព័ន្ធអាល្លឺម៉ង់

## ១. ការវិវត្តប្រវត្តិសាស្ត្រ

ដើម្បីបានយល់ដឹងនូវទំនាក់ទំនងរវាងរដ្ឋ និងព្រះវិហារសាសនាគ្រិស្ត ក្នុងប្រទេសអាល្លឺម៉ង់នាពេលបច្ចុប្បន្ន គេត្រូវតែគិតដល់ដំណើរប្រវត្តិជាសាស្ត្រយូរអង្វែងមួយ និងលក្ខណៈពិសេស នៃតំបន់វប្បធម៌សាសនាគ្រិស្តបច្ចឹមប្រទេស។ នៅសម័យវប្បធម៌មុនសាសនាគ្រិស្ត មានការរួបរួមគ្នារវាងរដ្ឋ និងសាសនា។ ភាពដាច់ពីគ្នារវាងព្រះវិហារ និងរដ្ឋបានកើតមានឡើងក្រោមឥទ្ធិពលនៃសាសនាគ្រិស្ត។

ក្នុងមជ្ឈឹមសម័យ (ចន្លោះសតវត្សទី៤ និង ទី១៥) ព្រះវិហារ និងរដ្ឋមានទំនាក់ទំនងគ្នាជាធ្លុងមួយយ៉ាងខ្លាំង។ សូម្បីតែក្រោយពីមានការកែទំរង់រួចមក(ប្រហែលឆ្នាំ១៦០០ក្រោយគ្រិស្តសករាជ) រាជបុរីត្រូវបានគ្រប់គ្រងដោយអ្នកដឹកនាំកាន់សាសនាគ្រិស្ត ដែលប្រជានុរាស្ត្រទាំងអស់ត្រូវតែដើរតាមនិកាយសាសនារបស់អ្នកដឹកនាំ។ ឧទាហរណ៍ ការចាកចេញពីរាជបុរីនិកាយប្រូតេស្តង់ទៅកាន់រាជបុរី និកាយកាតូលិក ក៏មានន័យថាជាការផ្លាស់ប្តូរនិកាយរបស់ខ្លួនដែរ។ ជាងនេះទៀត ចាប់តាំងពីដើមមជ្ឈឹមសម័យ អេវ៉េកកាតូលិកក៏ជាមេដឹកនាំបែបអាណាចក្រផងដែរ។ ភាគច្រើន ពួកគេគ្រប់គ្រងតំបន់តូចៗ ដែលពួកគេជាមេដឹកនាំបែបអាណាចក្រផង និងបែបសាសនាផង។ បញ្ហានេះបានកើតមានឡើងក្នុងរាជបុរីតូចៗជាច្រើនរបស់អាល្លឺម៉ង់ ដែលរដ្ឋតូចៗទាំងនេះ កកើតឡើងបន្ទាប់ពីមានការបែកខ្ញែកសាសនាគ្រិស្ត ជានិកាយចំនួនពីរគឺៈ ស្ថាប័ននិកាយប្រូតេស្តង់ និងស្ថាប័ននិកាយរ៉ូម៉ាំងកាតូលិក។

បន្ទាប់ពីមានបដិវត្តន៍នៅប្រទេសបារាំង ឆ្នាំ១៧៨៩មក ព្រះវិហារត្រូវបានគេដាក់ឱ្យនៅក្រៅស្ថាប័នរដ្ឋ។ នេះគឺជាការសម្តែងចេញនូវដំណើរការផ្ទេរអាណាចក្រភាព ដែលបានចាប់ផ្តើមឡើងក្នុងកំឡុងពេលនៃការយល់ដឹងច្បាស់ ផ្អែកលើការទាមទារឱ្យញែកព្រះវិហារ

ដាច់ចេញទាំងស្រុងពីរដ្ឋ។ ក្នុងឆ្នាំ១៨០៣ (ជាមួយ Reichsdeputationshauptschluss) បាន កើតមានឡើងនូវអាណាចក្រភាវូបនិយកម្មលើរាល់វិស័យសាសនាទាំងអស់ រួមទាំងទីវត្តអារាម របស់ Reich។ អតីតរាជបុរីសាសនាត្រូវបានបញ្ចូលទៅក្នុងរដ្ឋតូចៗអាល្លឺម៉ង់ ដែលទើបបង្កើត ឡើងក្រោមសម្ពាធរបស់មេដឹកនាំបារាំង ណាប៉ូឡេអុង ដែលមានបំណងបង្កើតទ្វីបអឺរ៉ុបថ្មី មួយ។

នៅពាក់កណ្ដាលទី២ នៃសតវត្សទី១៩ លោក **Otto von Bismarck** អធិការបតី អាល្លឺម៉ង់ បានប្រឈមមុខជាមួយព្រះវិហារនិកាយរ៉ូម៉ាំងកាតូលិក ដែលបច្ចុប្បន្នគេហៅថា "សង្គ្រាមវប្បធម៌" ដើម្បីកាត់បន្ថយឥទ្ធិពលព្រះវិហារ។ លោកបានដាក់បញ្ញត្តិទោសទណ្ឌចំពោះ បព្វជិតដែលធ្វើអធិប្បាយអវិជ្ជមានអំពីរដ្ឋ (ហៅថាបញ្ញត្តិទេសនា) លោកបានដាក់ឱ្យនៅក្រៅ ច្បាប់នូវសេចក្ដីបង្គាប់បញ្ជា របស់និកាយយេស៊ូអ៊ីត ដាក់ឱ្យមានច្បាប់ត្រួតពិនិត្យមើលសាលា រៀនផ្នែកសាសនា ដែលស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋ Pruss ហើយបានដាក់បញ្ចូលឱ្យមាន ច្បាប់អាពាហ៍ពិពាហ៍ផងដែរ។ ក៏ប៉ុន្តែ វិធានការរបស់លោក **Bismarck** មិនបានធ្វើឱ្យប៉ះ ពាល់ដល់ព្រះវិហារសាសនា នានាឡើយ ផ្ទុយទៅវិញបានពង្រឹងគណបក្សរ៉ូម៉ាំងកាតូលិកអាល្លឺ-ម៉ង់ ដែលមានឈ្មោះថាគណបក្សនិយមកណ្ដាល ដែលធ្វើឱ្យចំនួនអ្នកគាំទ្រកើនឡើងទ្វេដង ហើយនេះ ក៏ជាលទ្ធផលនៃសង្គ្រាមវប្បធម៌។ រយៈពេល១៥ឆ្នាំក្រោយពីមានការចរចារជាមួយ ក្រុងរ៉ូមរួចមក នៅទីបញ្ចប់ កិច្ចពិភាក្សាទាំងនោះបានធ្វើឱ្យមានច្បាប់សន្តិភាព។ វិធានការ របស់លោក **Bismarck** ក្រោយមក ក៏អស់សុពលភាពជាបន្តបន្ទាប់។ ទោះជាយ៉ាងណាក៏ ដោយ ច្បាប់អាពាហ៍ពិពាហ៍ និងការត្រួតពិនិត្យមើលរបស់រដ្ឋទៅលើសាលារៀនពុំការផ្លាស់ប្ដូរ ឡើយរហូតមកដល់ពេលបច្ចុប្បន្ននេះ។

នៅឆ្នាំ១៩១៩ បន្ទាប់ពីសង្គ្រាមលោកលើកទី១ចប់ ការបែងចែករវាងព្រះវិហារ និង រដ្ឋត្រូវបានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញអាល្លឺម៉ង់។ រដ្ឋធម្មនុញ្ញវៃម៉ា (Weimar) បានចែងថា: ពុំ មានព្រះវិហាររដ្ឋឡើយ។ ដោយសារ តែបញ្ហានេះហើយ ទើបចាំបាច់ត្រូវតែរកឱ្យឃើញនូវ ទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋដើម្បីធ្វើការទូទាត់ចំពោះការទាមទារជាសារវ័ន្តទាំងនេះក្នុង ការបែងចែកយ៉ាងតឹងរឹង (ចាត់ទុកសាសនាជាបញ្ហាឯកជន) និងសេចក្ដីត្រូវការបុព្វសិទ្ធិ និង ការគាំពាររបស់រដ្ឋចំពោះព្រះវិហារ និងមូលនិធិសាសនាគ្រិស្តនៃសង្គម។ រដ្ឋសភាវៃម៉ាបានខិត

ដំដោះស្រាយដោយដាក់ចេញនូវកម្មវិធីនិយតកម្មមួយ ដែលគំនិតមូលដ្ឋាននៃកម្មវិធីនោះគឺសេរីភាពសាសនា អព្យាក្រិតភាពខាងមនោគមវិជ្ជារបស់រដ្ឋ និងស្វ័យសំរេចភាពរបស់សហគមន៍សាសនាទាំងអស់។ ការបំពេញការងារសាសនាត្រូវបានផ្តាច់ចេញពីរដ្ឋ ក៏ប៉ុន្តែវានៅតែជាបញ្ហាសាធារណៈដដែល។ ទំនាក់ទំនង រវាងព្រះវិហារ និងរដ្ឋក្នុងប្រទេសអាល្លឺម៉ង់ត្រូវចាត់ទុកថាជាការបែងចែកបែបទន់ខ្សោយមួយ។ បើទោះជាមានអព្យាក្រិតភាព ផ្នែកមនោគមវិជ្ជារបស់រដ្ឋក៏ដោយ ក៏ការបែងចែករវាងព្រះវិហារ និងរដ្ឋមិនមានលក្ខណៈទាំងស្រុងឡើយ។ ផ្ទុយទៅវិញព្រះវិហារ និងរដ្ឋបានធ្វើសកម្មភាពក្នុងភាពជាដៃគូ លើវិស័យជាច្រើនទាំងបញ្ហាសាធារណៈ និងបញ្ហាវប្បធម៌ “res mixtae”។ បញ្ហានេះមានលក្ខណៈច្បាស់លាស់ណាស់ ដោយមានការទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញ អំពីតួនាទីរបស់ព្រះវិហារក្នុងកិច្ចការសាធារណៈ។ មានន័យថា ព្រះវិហារទទួលខុសត្រូវជួយប្រជាជន រួមចំណែកទទួលខុសត្រូវចំពោះការងារសកលលោក ហើយសហការគ្នាដើម្បីប្រយោជន៍រួម។ មាត្រានៃច្បាប់រដ្ឋធម្មនុញ្ញវៃម៉ា (Weimar) ស្តីអំពីទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋបានបង្ហាញឱ្យឃើញថាជាគំរូបទដ្ឋានយូរអង្វែង និងមានលក្ខណៈទន់ភ្លន់ ដែលមាត្រាទាំងនោះត្រូវបានរក្សាទុកដដែលនៅក្នុងរដ្ឋធម្មនុញ្ញទីក្រុងបុន (Bonn constitution) បន្ទាប់ពីសង្គ្រាមលោកលើកទី២ ឆ្នាំ១៩៤៩ (មាត្រា១៤០ នៃរដ្ឋធម្មនុញ្ញអាល្លឺម៉ង់)។

## ២. ទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋនាពេលបច្ចុប្បន្ន

ចាប់តាំងពីសង្គ្រាមលោកលើកទី២មក ទំនាក់ទំនងថ្មីមួយរវាងព្រះវិហារ និងរដ្ឋបានកើតចេញជារូបរាងក្នុងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមទំរង់មួយ ដែលធ្វើឱ្យពេញចិត្តពេញថ្លើមសំរាប់មនុស្សពាក់ព័ន្ធគ្រប់រូប។ ទំនាក់ទំនងនេះ មានលក្ខណៈទូលំទូលាយជាងការចូលរួមវិភាគទានចំណែកតូចណាមួយ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់សាធារណៈសហព័ន្ធ។ នាពេលបច្ចុប្បន្ន សហគមន៍របស់យើងរស់នៅជាមូលដ្ឋាន តាមប្រការដែលថា ព្រះវិហារមិនមែនគ្រាន់តែចូលរួមចំណែកក្នុងកិច្ចការផ្ទាល់របស់ខ្លួនទេ។ សហប្រតិបត្តិការរបស់ព្រះវិហារ ជាមួយរដ្ឋគឺផ្អែកលើភាពជាដៃគូរ។ ពុំមានការដាក់កំរិតលើសេរីភាពណាឡើយ ដែលចាំបាច់ដើម្បីបំពេញកាតព្វកិច្ចជាក់លាក់ ហើយព្រះវិហារត្រៀមខ្លួនធ្វើសហការ

ការងារជាមួយជានិច្ច។ ចាំបាច់យកបញ្ហានេះមកគិតគូផងដែរ ទប់ទល់ជាមួយប្រវត្តិសាវតានៃការបង្រួបបង្រួមទ្វីបអឺរ៉ុប។

ទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋក្នុងប្រទេសអាល្លឺម៉ង់ ត្រូវបានគ្រប់គ្រងដោយច្បាប់សាសនារដ្ឋ។ ទំនាក់ទំនងទាំងនេះ ត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ តាមអនុរូបសញ្ញា និងកិច្ចសន្យាព្រះវិហារប្រូតេស្តង់ ព្រមទាំងតាមច្បាប់ និងបទបញ្ញាត្តិជាច្រើនប្រភេទក្នុងវិស័យច្បាប់ខុសៗគ្នា។ ប្រព័ន្ធច្បាប់រដ្ឋ និងព្រះវិហារនៅតែមានលក្ខណៈដាច់ដោយឡែកពីគ្នា ក្នុងច្បាប់សាសនារដ្ឋ ខ្លឹមសារសំខាន់របស់បព្វជិត ពោលគឺកិច្ចការខាងក្នុងផ្ទាល់របស់ខ្លួន បេសកកម្ម និង ការកំណត់និយមន័យនូវឧត្តមគតិរបស់ខ្លួន Selbstverständnis មិនអាចត្រូវបានរារាំងដោយរដ្ឋឡើយ។ ព្រះវិហារទាមទារមិនឱ្យមានការត្រួតពិនិត្យមើលពីលើរដ្ឋ។ ដូចគ្នានេះដែរ រដ្ឋសន្មតថាពុំមានការត្រួតពិនត្យមើលពីលើព្រះវិហារវិញដែរ ប៉ុន្តែត្រូវគោរពបេសកកម្ម និងសេវាសាធារណៈរបស់ព្រះវិហារ។

រដ្ឋធម្មនុញ្ញគោរពគោលការណ៍ទំនុកបំរុង ហើយតាមគោលការណ៍នោះ ភារកិច្ចរបស់រដ្ឋមិនត្រឹមតែអនុគ្រោះកំលាំងសេរីក្នុងសង្គមប៉ុណ្ណោះទេ តែថែមទាំងគាំទ្រ និងអភិវឌ្ឍកំលាំងទាំងនេះយ៉ាងសកម្មទៀតផង។ ជាការពិតណាស់ថា រដ្ឋបំពេញការងារត្រួតត្រាមួយចំនួនចំពោះព្រះវិហារ ជាឧទាហរណ៍ បទបញ្ញារ និងការយកពន្ធដារពីព្រះវិហារ ដែលសមាជិកព្រះវិហារសាសនារ៉ូម៉ាំងកាតូលិក និងប្រូតេស្តង់បានបង់ពន្ធជូន។ រដ្ឋប្រមូលពន្ធទាំងនេះ ហើយប្រគល់ពន្ធទៅឱ្យព្រះវិហារវិញ។ ជាងនេះទៀត រដ្ឋធានាគាំទ្រខាងវិស័យសាសនាតាមស្ថាប័ននានាដែលស្ថាប័នទាំងនោះ មិនអាចដំណើរការទៅបាន បើសិនគ្មានជំនួយពីរដ្ឋ។ ឧទាហរណ៍ តាមមន្ទីរពេទ្យ កំលាំងការពារជាតិ មន្ទីរឃុំឃាំង និងអង្គរក្សការពារព្រំដែនសហព័ន្ធ។ រដ្ឋក៏ត្រូវផ្តល់សុវត្ថិភាពផ្នែកហិរញ្ញវត្ថុដល់សកម្មភាពរបស់ព្រះវិហារផងដែរ ដោយបង់ថ្លៃលើចំណាយនានា។ មានសហប្រតិបត្តិការជិតស្និតដាច់ដោយឡែកមួយរវាងព្រះវិហារ និងរដ្ឋ ខាងវិស័យជំនួយសង្គមកិច្ចក្នុងផ្នែកអប់រំ និងសុខមាលភាពយុវជន។ នៅប្រទេសអាល្លឺម៉ង់ សាលារៀនចំនួន១០% រៀបចំ និងគ្រប់គ្រងដោយព្រះវិហារ ក្នុងនោះរួមមានមតេយ្យសាលាផងដែរ។ សហប្រតិបត្តិការលើវិស័យផ្សេងទៀតរវាងព្រះវិហារ និងរដ្ឋ មានការបង្ហាត់បង្រៀនសាសនាតាមសាលារដ្ឋ ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ តែខ្លឹមសារព្រះវិហារជាអ្នកទទួលខុស

ត្រូវរៀបចំ ហើយក៏មានមហាវិទ្យាល័យខាងទេវវិទ្យានៅតាមសាកលវិទ្យាល័យរដ្ឋ និងវិទ្យាស្ថានអប់រំរបស់ព្រះវិហារ ដែលកម្មវិធីអប់រំ និងកំរិតសញ្ញាប័ត្រត្រូវបានរដ្ឋទទួលស្គាល់ជាផ្លូវការ។

ក្នុងវិស័យសេវាសង្គមកិច្ច រដ្ឋធានាអាទិភាពនានាចំពោះអង្គភាពផ្តល់សេវាថែទាំឯកជន ក្នុងនោះមានព្រះវិហារ អនុលោមតាមគោលការណ៍ស្តីអំពីការទំនុកបំរុង។ ស្ថាប័នសាធារណៈ ចាត់វិធានការសកម្មភាព តែនៅពេលមានការប្តេជ្ញាចិត្តពិតប្រាកដ ហើយព្រះវិហារមិនអាចផ្តល់សេវាសង្គមកិច្ចទាំងនោះបាន។

## ៣. ឥទ្ធិពលរបស់ព្រះវិហារលើនយោបាយ

ព្រះវិហារ ក៏មានឥទ្ធិពលលើកិច្ចការនយោបាយផងដែរនៅប្រទេសអាល្លឺម៉ង់។ តាមរយៈភាពតំណាងរបស់ខ្លួនក្នុងអាជ្ញាធររដ្ឋ និងអង្គការនីតិប្បញ្ញត្តិ ព្រះវិហារចំនួនពីរបានបង្កើតអង្គការតំណាងនៅថ្នាក់សហព័ន្ធ និងថ្នាក់រដ្ឋ ដូចជា: នាយកដ្ឋានស្នងការអែវ៉ែកអាល្លឺម៉ង់ (ការិយាល័យរ៉ូម៉ាំងកាតូលិក) និងការិយាល័យតំណាងនៃក្រុមប្រឹក្សាព្រះវិហារប្រូតេស្តង់ (Rat der Evangelischen Kirche) ក្នុងប្រទេសអាល្លឺម៉ង់។ តាងនាមឱ្យអាជ្ញាធរ ព្រះវិហារទាំងពីរនិកាយនេះ អង្គការតំណាងទាំងពីរ មានភារកិច្ចយ៉ាងសកម្មក្នុងបញ្ហានយោបាយចំពោះស្ថាប័នរដ្ឋាភិបាលសហព័ន្ធ គណបក្ស និងចំពោះអង្គការនានា ដែលតំណាងសង្គមស៊ីវិលថ្នាក់ ជាតិ និងអង្គការអន្តរជាតិ។

នាយកដ្ឋានស្នងការអែវ៉ែកអាល្លឺម៉ង់ និងការិយាល័យតំណាងនៃក្រុមប្រឹក្សាព្រះវិហារប្រូតេស្តង់ (Rat der Evangelischen Kirche) ក្នុងប្រទេសអាល្លឺម៉ង់ តាមដានសង្កេតការជាពិសេសលើការអភិវឌ្ឍទូទៅនៃវិស័យសង្គមកិច្ច នយោបាយ និងផែនការកសាងច្បាប់នានារបស់សហព័ន្ធ។ អង្គការនេះក៏ចូលរួមផងដែរក្នុងការរៀបចំធ្វើច្បាប់ និងសេចក្តីសំរេចផ្នែកនយោបាយ រួមទាំងការចេញសេចក្តីថ្លែងការ ព្រមទាំងការអនុវត្តសេចក្តីសំរេចរបស់ស្ថាប័នខ្លួន។ ការិយាល័យស្នងការធ្វើការដោយសហការជាមួយអង្គការដទៃទៀតដូចជា: អង្គការ និងគណៈកម្មាធិការសន្និសីទអែវ៉ែកអាល្លឺម៉ង់ និងសមាគមព្រះវិហារនិកាយដូចគ្នានៅប្រទេសអាល្លឺម៉ង់ ក្រុមដឹកនាំបព្វជិត និងព្រះវិហារនិកាយដូចគ្នា ការិយាល័យដទៃទៀតនៃសន្និសីទអែវ៉ែកអាល្លឺម៉ង់ គណៈកម្មាធិការកណ្តាលរ៉ូម៉ាំងកាតូលិកអាល្លឺម៉ង់ ក្រុមសាវ៉កបេសកជន ការិយាល័យ

រ៉ូម៉ាំងកាតូលិកក្នុងរដ្ឋនានា ព្រមទាំងអ្នកគ្រប់គ្រងក្រុមប្រឹក្សាព្រះវិហារប្រូតេស្តង់ ក្នុងប្រទេសអាល្លឺម៉ង់ ប្រចាំសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសហភាពអឺរ៉ុប។

## ៤. ទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋ ក្នុងទ្វីបអឺរ៉ុប

ក្នុងប្រទេសនានានៃទ្វីបអឺរ៉ុប ទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋមានភាពខុសប្លែកពីគ្នាយ៉ាងខ្លាំង។ ឧទាហរណ៍ មានរដ្ឋប្រូតេស្តង់ ឬព្រះវិហាររបស់ប្រជាជនក្នុង Scandinavia។ មានលក្ខណៈប្លែកពិសេសនៃព្រះវិហាររបស់រដ្ឋនិកាយអង់គ្លីខិន (Anglican) ក្នុងប្រទេសអង់-គ្លេស (ព្រះវិហារអង់គ្លេស)។ មានទំនាក់ទំនងពិសេស និកាយអសដុក (វិន័យចាស់) របស់ក្រិចរវាងព្រះវិហារ និងរដ្ឋ ដែលច្បាប់រដ្ឋធម្មនុញ្ញធានាថា ពាក្យពេចន៍នៅក្នុងព្រះគម្ពីរពុំមានការកែប្រែដាច់ខាត។ មានកិច្ចព្រមព្រៀងនៅប្រទេសប៉ូឡូញរវាងព្រះវិហារ និងរដ្ឋ និងការអនុវត្តការបែងចែកទន់ខ្សោយនៅប្រទេសអាល្លឺម៉ង់។ ក្រៅពីនោះ មានរដ្ឋធម្មនុញ្ញបារាំងដែលប្រកាសប្រទេសបារាំងជាសាធារណៈរដ្ឋគ្រហស្ថ។

## ៥. ព្រះវិហារ និងរដ្ឋ ក្នុងសេចក្តីព្រាងរដ្ឋធម្មនុញ្ញអឺរ៉ុប

ការបង្ហាញពីភាពខុសប្លែកគ្នា ស្តីពីទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋបានផ្តល់នូវខ្លឹមសារដល់កិច្ចពិភាក្សាគ្នាយ៉ាងច្រើន ក្នុងការជជែកដេញដោលគ្នា ក្នុងពេលព្រាងរដ្ឋធម្មនុញ្ញអឺរ៉ុប។ ជាពិសេសបញ្ហាលើកយកមកពិភាក្សា ថាតើបុព្វបទរដ្ឋធម្មនុញ្ញគប្បីមាននិយាយយោងទៅរកព្រះដែរឬអត់។ លទ្ធផលពីការខិតខំប្រឹងប្រែងទាំងនេះ បានបង្ហាញថា សេចក្តីយោងទៅរកព្រះតំណាងឱ្យអញ្ញត្រកម្មមួយ ជាជាងវិធានក្នុងច្បាប់រដ្ឋធម្មនុញ្ញ ហើយដូច្នេះមិនត្រូវដាក់បញ្ចូលក្នុងបុព្វបទឡើយ។ មានប្រទេសសមាជិកសហភាពអឺរ៉ុបចំនួន៥ប៉ុណ្ណោះ (អាល្លឺម៉ង់ ក្រិច អៀកឡង់ ដាណឺម៉ាក និងប៉ូឡូញ) មានសេចក្តីយោងទៅរកព្រះក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន។ ភាពជំទាស់នឹងបញ្ហានេះ កើតមានឡើងជាពិសេសពីប្រទេសបារាំង ដែលមិនប្រកាន់យកសាស-នាជាផ្លូវការ ហើយក៏ចេញពីប្រទេសអេស្ប៉ាញផងដែរ ដោយសារតែចំណងទាក់ទងយ៉ាងជិតស្និតរវាងព្រះវិហារ និងរដ្ឋ ក្រោមអំណាចផ្តាច់ការហ្វ្រង់កូ (Franco) ពីឆ្នាំ១៩៣៦ ដល់១៩៧៧។ សេចក្តីថ្លែងក្នុងបុព្វបទដែលថា តម្លៃជាមូលដ្ឋានរបស់អឺរ៉ុប ព្រមទាំងកេរដំណែលវប្បធម៌ និងមនុស្សជាតិក៏ស្ថិតក្នុងកេរដំណែលសាសនាគ្រិស្តនោះ មិនបានទាក់ទាញឱ្យមានសំលេងគាំទ្រ

ភាគច្រើនឡើយ។ ដូច្នេះគេបានដកចេញវិញនូវពាក្យពេចន៍ "កេរដំណែលសាសនា" សូម្បីតែពាក្យពេចន៍ផ្នែកទស្សនៈទាន "មរតកខាងផ្លូវអារម្មណ៍" ដែលចាំបាច់អោយមានការការពារក៏ដោយ។

ការរៀបចំទំនាក់ទំនងរវាងព្រះវិហារ និងរដ្ឋនៅកំរិតថ្នាក់អឺរ៉ុបត្រូវបានសរសេរក្នុងសេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញជាមាត្រាស្តីអំពីសាសនាគ្រិស្ត ដែលចែងថា "សហភាពគោរពឋានៈដែលព្រះវិហារ និងសហគមន៍ ឬសមាគមសាសនាមានក្នុងរដ្ឋជាសមាជិកអនុលោមតាមមាត្រាច្បាប់របស់ខ្លួន ហើយមិនធ្វើឱ្យឋានៈនោះចុះខ្សោយបានទេ (តាមមាត្រាទី៥១ កថាខ័ណ្ឌទី១ នៃសេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញសហភាពអឺរ៉ុប)។ តាមប្រវត្តិសាស្ត្រអឺរ៉ុប ជាការពិតសហភាពនេះជាអង្គការអាណាចក្រ ក៏ប៉ុន្តែមិនជាគ្រហស្ថទេ ហេតុដូច្នេះហើយសហភាពអឺរ៉ុបមានជំហរអព្យាក្រិតលើសាសនា និងទស្សនៈវិជ្ជាជីវិត។ វាមិនមែនជាតំបន់គ្មានសាសនាទេ ហើយក៏មិនប្រឆាំងនឹងសាសនាដែរ។ សហភាពមិនទទួលយកព្រះវិហារ និងសហគមន៍សាសនាថាជាការសម្តែងសេរីភាពសាសនាជាបុគ្គលទេ ហើយសហភាពមិនបំបាត់សាសនាដល់ការប្រតិ-បត្តិជាឯកជនដែរ ផ្ទុយទៅវិញ ព្រះវិហារ និងនិកាយសាសនានានា អាចប្រតិបត្តិតាមជំនឿរបស់ខ្លួនជាសាធារណៈបាន ហើយបើមានការចូលរួមដោះស្រាយបញ្ហានានារបស់អឺរ៉ុប ក៏រឹតតែទទួលបាននូវការលើកទឹកចិត្តថែមទៀត។ ប្រការនេះមានចែងក្នុងមាត្រាស្តីពីព្រះវិហារថា: "សហភាពបើកឱ្យមានការជជែកពិភាក្សាជាទៀងទាត់ជាចំហរ និងប្រកបដោយតម្លាភាពជាមួយព្រះវិហារ (និងសហគមន៍) ដោយទទួលស្គាល់អត្តសញ្ញាណ និងការរួមចំណែកពិសេសរបស់ព្រះវិហារ" (មាត្រា៥១ កថាខ័ណ្ឌ៣ នៃសេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញសហភាពអឺរ៉ុប)។ មានព្រះវិហារចំនួន២ នៅប្រទេសអាល្លឺម៉ង់បានទទួចទាមទារយ៉ាងខ្លាំង ជាពិសេសលើបញ្ហានេះ។ សហភាពក៏ពឹងផ្អែកលើព្រះវិហារ និងសហគមន៍សាសនា ដែលជាអង្គការបែបសកលក្នុងសិទ្ធិផ្ទាល់របស់ខ្លួន ដើម្បីនាំយកគំនិត និងតម្លៃរបស់ខ្លួនទៅដល់សង្គម។

ឋានៈ និងសិទ្ធិពិសេសរបស់ព្រះវិហារ ក្នុងការជជែកពិភាក្សាផ្នែកនយោបាយក្នុងប្រទេសអាល្លឺម៉ង់ មានលក្ខណៈប្លែកពីគេ ហើយមិនមានជាទូទៅក្នុងរដ្ឋសមាជិកភាគច្រើន នៃទ្វីបអឺរ៉ុបទេ។ នៅទីបំផុតបញ្ញត្តិដែលមានចែងបែបនេះ មិនត្រូវបានគេឃើញមានក្នុងរដ្ឋធម្មនុញ្ញទាំងនោះឡើយ បើទោះជាបញ្ញត្តិបែបនេះ អាចមានក្នុងកិច្ចសន្យាព្រះវិហារ និងអនុរូបសញ្ញានានា

ក៏ដោយ។ ទាក់ទងនឹងកិច្ចដំណើរការផ្សាភ្ជាប់ ការបែបស្ថាប័នរវាងសាសនា និងនយោបាយ សេចក្ដីព្រាងច្បាប់រដ្ឋធម្មនុញ្ញនេះ មានលក្ខណៈស្និតស្នាលល្អជាមួយព្រះវិហារ ច្រើនជាងច្បាប់រដ្ឋធម្មនុញ្ញរបស់រដ្ឋសមាជិកភាគច្រើនរបស់សហភាពអឺរ៉ុប។

# យុត្តិធម៌សង្គមតាមទស្សនៈវិស័យព្រះពុទ្ធសាសនា

ព្រះទេពសត្ថា **ឃឹ សុវណ្ណរតនា** ព្រះរាជាគណៈថ្នាក់ចត្វា
សាកលវិទ្យាធិការរងនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

## ១. សេចក្តីផ្តើម

យុត្តិធម៌ គឺជាធម៌ដែលគួរកាន់យកសេចក្តីទៀងត្រង់ ការប្រព្រឹត្តិត្រឹមត្រូវ។ យុត្តិធម៌សង្គមមានន័យថា ការប្រព្រឹត្តត្រឹមត្រូវ និងមិនលំអៀងចំពោះមនុស្សគ្រប់រូបនៅក្នុងសង្គម។ យុត្តិធម៌សង្គម និយាយដល់ទស្សនៈនៃសង្គមមួយប្រកបដោយយុត្តិធម៌ ហើយវាមានវិសាលភាពលើសពីការគ្រប់គ្រងប្រកបដោយច្បាប់តែមួយមុខ។ វាផ្តោតទៅលើសង្គមមួយ ដែលផ្តល់នូវភាពត្រឹមត្រូវ ភាពមិនលំអៀង និងផលប្រយោជន៍ស្មើគ្នា ដល់ក្រុមមនុស្ស និងបុគ្គលគ្រប់រូប។

យុត្តិធម៌សង្គមគឺជាបញ្ហាទស្សនៈវិជ្ជាផង និងជាបញ្ហាសំខាន់ផ្នែកនយោបាយ និងសេដ្ឋកិច្ចផង។ គេអាចនិយាយបានថា មនុស្សគ្រប់គ្នាចង់រស់នៅក្នុងសង្គមដែលមានយុត្តិធម៌។ មនោគមវិជ្ជានយោបាយផ្សេងៗមាន ការយល់ឃើញខុសគ្នាថា តើយុត្តិធម៌សង្គមពិតប្រាកដនោះដូចម្តេច? ពាក្យយុត្តិធម៌សង្គមត្រូវបានប្រើប្រាស់ដោយមនោគមវិជ្ជាទាំងឡាយ ដែលជឿថាសង្គមបច្ចុប្បន្នមានភាពអយុត្តិធម៌ខ្លាំងណាស់ ហើយជាទូទៅពួកទាំងអស់នេះ ជាពួកមនោគមវិជ្ជាឆ្វេងនិយម ដែលគាំទ្រជំហរថា ទាល់តែមានការបែងចែកធនធានឡើងវិញ ទើបអាចធ្វើឱ្យសង្គមមានសមភាពជាងពេលនេះ។ ចំណែកពួកស្តាំនិយមមានការយល់ឃើញផ្សេងស្តីពីយុត្តិធម៌សង្គម ប៉ុន្តែជាទូទៅគេជឿថា យុត្តិធម៌សង្គមអាចសម្រេចទៅបានតាមរយៈការអនុវត្តទីផ្សារសេរី ការលើកស្ទួយសប្បុរសធម៌ និងការធ្វើទាន។ ទោះបីយ៉ាងណា មនោគមវិជ្ជាស្តាំនិយម និងឆ្វេងនិយមហាក់ដូចជាយល់ស្របគ្នាលើសារៈសំខាន់ នៃនីតិរដ្ឋ សិទ្ធិមនុស្ស និងប្រព័ន្ធសុខមាលភាពសង្គមមួយចំនួនទៀត។

យុត្តិធម៌សង្គមគឺជាប្រធានបទដែលគេតែងនិយាយយ៉ាងទូលំទូលាយ និងគេត្រូវការបំផុត ប៉ុន្តែសង្គមស្ទើរតែទាំងអស់មិនអាចសម្រេចបាន។ មនុស្សជាច្រើន ចង់ឱ្យគេផ្តល់យុត្តិធម៌ដល់ខ្លួន តែគេមិនដែលគិតមួយខណៈណាទាល់តែសោះ ថាតើអ្វីដែលគេកំពុងធ្វើមានយុត្តិធម៌

សម្រាប់អ្នកដទៃដែរឬទេ?។ ទង្វើនេះ បើតាមព្រះពុទ្ធសាសនា កើតឡើងដោយសារតែអាត្មានិយម និងភាពល្ងង់ខ្លៅរបស់គេ។ នៅក្នុងពិភពលោកបច្ចុប្បន្ន ទោះបីជាបច្ចេកវិទ្យា មានការជឿនលឿនលើសពីសម័យកាលណាទាំងអស់ ក៏មនុស្ស នៅតែជួបប្រទះនឹងបញ្ហាច្រើនជំពូក ដូចជាការកើនឡើងនៃឧក្រិដ្ឋកម្ម អំពើហិង្សាក្នុងសង្គម ការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងអំពើអយុត្តិធម៌ផ្សេងៗទៀត កើតឡើងនៅពាសពេញពិភពលោក។ ប្រសិនបើយើងគ្រាន់តែអាន ឬស្ដាប់ប្រព័ន្ធសារព័ត៌មានភ្លាមនោះ យើងនឹងដឹងថា ការរំលោភបំពានទាំងអស់នោះបានកំពុងកើតឡើងគ្រប់ពេលទីកន្លែង។

ទោះបីជាព្រះពុទ្ធបានបង្រៀនអំពីការចម្រើននូវមេត្តា ករុណា មុទិតា និងឧបេក្ខាសម្រាប់មនុស្សប្រតិបត្តិក៏ដោយ យើងសង្កេតឃើញថា នៅក្នុងប្រទេសដែលមានប្រជាពលរដ្ឋភាគច្រើនកាន់ព្រះពុទ្ធសាសនា មនុស្សជាច្រើនបានកំពុងរងនូវការរំលោភសិទ្ធិ និងអំពើអយុត្តិ-ធម៌។ មនុស្សជាច្រើននៅក្នុងប្រទេសទាំងនេះ ត្រូវបានគេដកហូតយុត្តិធម៌ និងសិទ្ធិជាមូលដ្ឋានជាច្រើនទសវត្សរ៍។ ជាការពិត ប្រសិនបើមនុស្សម្នាទាំងនោះ ប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយអនុវត្តតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ការរំលោភសិទ្ធិមនុស្ស និងអយុត្តិធម៌សង្គមមិនអាចកើតឡើងបានទេ ។ ផ្ទុយទៅវិញ មនុស្សម្នាទាំងនោះនឹងរស់នៅប្រកបដោយសុខដុមរមនា និងភាពសប្បាយរីករាយជាមួយនឹងយុត្តិធម៌ និងសិទ្ធិរបស់គេយ៉ាងពេញលេញ។ ឥឡូវនេះ យើងនឹងពិភាក្សាលើពាក្យប្រៀនប្រដៅចម្បងៗមួយចំនួនរបស់ព្រះពុទ្ធ ដែលជាប់ទាក់ទិននឹងយុត្តិធម៌សង្គម ។

## ២. មនុស្សមានសមធម៌ពីកំណើត

ព្រហ្មញ្ញសាសនាបានបង្រៀនថា មនុស្សត្រូវបានបង្កើតឡើងដោយព្រះព្រហ្មចេញពីផ្នែកផ្សេងៗនៃសរីរៈរបស់ព្រះអង្គ ហើយអាស្រ័យលើវណ្ណៈរបស់គេ មនុស្សត្រូវបានផ្ដល់ឱ្យនូវការងារផ្សេងៗដើម្បីបំពេញ។ អ្នកដែលកើតក្នុងវណ្ណៈទាប ត្រូវធ្វើការងារថោកទាប និងត្រូវប្រមាទមាក់ងាយដោយពួកវណ្ណៈខ្ពស់។ ប៉ុន្តែ ព្រះពុទ្ធបង្រៀនថា មនុស្សកើតមកមានសិទ្ធិស្មើគ្នា សកម្មភាពរបស់គេប៉ុណ្ណោះ ដែលធ្វើឱ្យមានភាពខុសគ្នាៈ

*"មនុស្សមិនមែនជាព្រាហ្មណ៍ដោយកំណើត*

*មិនមែនដោយកំណើត មនុស្សមិនមែនព្រាហ្មណ៍នោះទេ*

*ដោយការងារ បុគ្គលជាព្រាហ្មណ៍*

*ដោយការងារ បុគ្គលមិនមែនជាព្រាហ្មណ៍។*

*បុគ្គលជាកសិករដោយសារទង្វើរបស់គេ*

*ហើយដោយសារទង្វើ បុគ្គលក្លាយជាវិចិត្រករ។*

*បុគ្គលជាពាណិជ្ជករ ដោយសារទង្វើរបស់គេ*

*ដោយសារទង្វើ បុគ្គលក្លាយជាខ្ញុំបម្រើគេ។*

*បុគ្គលជាបព្វជិតដោយសារទង្វើរបស់គេ*

*ហើយដោយសារទង្វើ គេក្លាយជាអ្នកដឹកនាំផងដែរ។"*

## ៣. ព្រះពុទ្ធសាសនា និងសិទ្ធិមនុស្ស

សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស បានលើកស្ទួយនូវការគោរព និងការអនុវត្តជាសកលនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសម្រាប់មនុស្សគ្រប់រូបដោយគ្មានភាពរើសអើង ព្រោះពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ។ គោលបំណងនៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស គឺការអភិវឌ្ឍសេរីភាព សមភាព ឧត្តមភាព យុត្តិធម៌ សិទ្ធិ និងស្មារតីភាតរភាព នៅក្នុងពិភពលោក។ គោលការណ៍ទាំងអស់នេះ ស្របគ្នាទាំងស្រុងជាមួយនឹងគោលការណ៍ ព្រះពុទ្ធសាសនា ហើយយើងអាចនិយាយបានថាគោលការណ៍ទាំងអស់នេះគ្មានអ្វីថ្មី ចំពោះព្រះពុទ្ធសាសនាទេ ។ ឧត្តមគតិសិទ្ធិមនុស្សនៅក្នុងព្រះពុទ្ធសាសនាកើតមានឡើងពីការសន្មត់ជាមូលដ្ឋានពីរគឺៈ ទស្សនវិជ្ជា និងសីលធម៌។ ព្រះពុទ្ធសាសនាសម្តែងថា មនុស្សកើតមកមានសេរីភាពពេញលេញ និងមានការទទួលខុសត្រូវ។ សេរីភាពទាំងនោះស្ថិតនៅក្រោមច្បាប់កម្មផលតែប៉ុណ្ណោះ មិនមែនជាការបង្កើតឡើងរបស់ព្រះជាម្ចាស់ទេ ដូច្នេះវាសនារបស់មនុស្សស្ថិតនៅក្នុងដៃរបស់ពួកគេផ្ទាល់។ ព្រះធម៌ដែលព្រះពុទ្ធបានប្រៀនប្រដៅមានទំនាក់ទំនង និងអត្ថន័យជ្រាលជ្រៅ។ វាមានទាំងទ្រឹស្តីទស្សនវិជ្ជា និងសីលធម៌ដែលទូន្មានអោយប្រព្រឹត្តល្អ ការគឹតគូដល់សិទ្ធិនិងភារកិច្ច។ ព្រះពុទ្ធពុំបានបង្រៀនអំពីនយោបាយឡើយ ប៉ុន្តែទ្រង់បានប្រៀនប្រដៅអំពីសីលធម៌គ្រួសារ និងសង្គមដែលផ្តល់ឱកាសដល់ជនគ្រប់រូបទទួល

បានន្ទូវតំលៃនៅក្នុងសង្គមដោយមិនមានការរើសអើង ឋានៈ ភេទ ព្រះសង្ឃ ឬគ្រហស្ថឡើយ។ ប្រសិនបើយើងសិក្សាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធឱ្យបានច្បាស់លាស់ យើងនឹងឃើញថាព្រះធម៌របស់ព្រះពុទ្ធគឺជាច្បាប់សាកល ដែលមនុស្សគ្រប់រូបអាចប្រតិបត្តិបាន ។

## ៤. សមភាព និងឧត្តមភាព

នៅសម័យពុទ្ធកាល ស្ថានភាពសាសនា និងទស្សនៈវិជ្ជាក្នុងប្រទេសឥណ្ឌាមិនទាន់ជាប្រព័ន្ធមានការចាត់ចែងច្បាស់លាស់នោះទេ វាគឺជាស្ថានភាពមួយមានភាពច្របូកច្របល់។ គ្រូសាសនា តាបស ឥសីជាច្រើន បានប្រកាសន្ទូវទស្សនៈវិជ្ជា និងបរមត្ថវិជ្ជារបស់ពួកគេ ប៉ុន្តែពួកគេទាំងអស់មានការខ្វែងគំនិតគ្នា ដែលបង្កឱ្យមានការជជែកវែកញែកផ្នែកសាសនា និងទស្សនៈវិជ្ជា (religious and philosophical debates) យ៉ាងផុលផុស។ ប្រសិនបើយើងក្រឡេកមើលស្ថានភាពសង្គមនាសម័យនោះ យើងនឹងឃើញថា ទស្សនៈវិស័យសមភាពសង្គមមិនមានទេ ។ សង្គមមានវណ្ណៈបួន ហើយមនុស្សភាគច្រើនស្ថិតនៅក្នុងវណ្ណៈទាបបំផុត ឬវណ្ណៈដែលគេស្អប់ខ្ពើម។ មនុស្សទាំងអស់នោះត្រូវគេដកហូតសិទ្ធិផ្នែកបញ្ញាស្មារតី និងសិទ្ធិផ្នែកយុត្តិធម៌សង្គម។ ស្ត្រីនៅសម័យនោះមានតំលៃទាបណាស់ ហើយគ្មានសមភាពឡើយ។ ការសំលាប់សត្វបូជាក្នុងសាសនាសំរាប់មនុស្សពិសេសណាម្នាក់ គឺជារឿងសាម័ញ្ញ។ នៅសម័យនោះ ការទទួលយកប្រព័ន្ធវណ្ណៈ និងការសម្លាប់សត្វដើម្បីបូជាក្នុងនាមព្រះអាទិទេព បញ្ជាក់ពីការប្រកាន់ខ្ជាប់ន្ទូវសាសនា និងការប្រតិបត្តិន្ទូវលទ្ធិណាមួយ។ ក្រោយពេល បានត្រាស់ដឹងន្ទូវសម្មាសម្ពោធិញ្ញាណ ព្រះពុទ្ធបានរកឃើញន្ទូវសច្ចធម៌ ដោយព្រះអង្គឯង ហើយបានបង្រៀនន្ទូវព្រះធម៌ដែលផ្ទុយពីទស្សនៈជាប្រពៃណីទាំងនោះ។ ព្រះពុទ្ធបានសំដែងថា ព្រះធម៌របស់ព្រះអង្គគឺផ្ទុយទៅនឹងជំនឿដែលកំពុងស្ថិតនៅជាធរមាន សម័យនោះ (បដិសោតគាមី)។ វាជាការសំខាន់ណាស់ដែលត្រូវស្វែងយល់ថា ធម៌របស់ព្រះពុទ្ធមិនមែនជាប្រភេទពំនោលសាសនាដើម្បីផ្គាប់ចិត្តព្រះអាទិទេព (psalms) នោះទេ ប៉ុន្តែជាមាគ៌ាដើម្បីអភិវឌ្ឍបញ្ញា និងករុណា ចំពោះសព្វសត្វទាំងអស់។ ក្នុងព្រះពុទ្ធសាសនា សេរីភាពនៃមនុស្សគ្រប់រូបចាប់ផ្តើមតាំងពីកំណើតរបស់គេ។ ដូច្នេះ ព្រះពុទ្ធសាសនាទទួលស្គាល់ថា មនុស្សគ្រប់រូបមានសមភាព សេចក្តីថ្លៃថ្នូរ សិទ្ធិ និងការទទួលខុសត្រូវ។ ព្រះពុទ្ធទ្រង់សម្តែងថា "ខ្លួនជាទីពឹងរបស់ខ្លួន តើមានទីពឹងអ្វី

ប្រសើរជាង" ព្រះអង្គបន្ថែមថា "សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធអាស្រ័យលើខ្លួនឯងផ្ទាល់ គ្មានបុគ្គលដទៃណាអាចធ្វើឱ្យខ្លួនបរិសុទ្ធឡើយ"។

## ៥. ឋានៈរបស់មនុស្ស

ក្រោយពីបានត្រាស់ដឹងនូវសច្ចធម៌ ព្រះពុទ្ធបានបង្រៀនអំពីមជ្ឈិមាបដិបទា (ផ្លូវកណ្តាល) ដែលប្រាសចាកអន្តធម៌ពីរយ៉ាងគឺៈ ការជាប់ជំពាក់ក្នុងកាម (កាមសុខល្លិកានុយោគ) និងការធ្វើទារុណកម្មដល់ខ្លួន (អត្តកិលមថានុយោគ) ដែលព្រះអង្គបានសាកល្បងដោយខ្លួនព្រះអង្គផ្ទាល់ មុនពេលព្រះអង្គរកឃើញនូវមជ្ឈិមាបដិបទា។ មជ្ឈិមាបដិបទាមិនមែនជាសិទ្ធន្ត (dogma) នោះទេ ប៉ុន្តែជាមាគ៌ាបដិបត្តិដើម្បីរំដោះមនុស្សចេញពីសេចក្តីទុក្ខ និងសម្រេចនូវការត្រាស់ដឹង។ ព្រះអង្គបានឧទ្ទិសការត្រាស់ដឹង និងការសម្រេចនូវព្រះនិព្វានរបស់ព្រះអង្គចំពោះការប្រតិបត្តិប្រកបដោយវីរិយភាពក្នុងឋានៈជាមនុស្ស។ ធម៌របស់ព្រះពុទ្ធអាចអនុវត្តបានចំពោះមនុស្សប្រុសស្រី គ្រប់ឋានៈទាំងអស់ ដូចជា ព្រះមហាក្សត្រ រាស្ត្រ ពួកវណ្ណៈខ្ពស់ ពួកវណ្ណៈទាប ពាណិជ្ជករ និងអ្នកសុំទាន អ្នកបួស និងអ្នកធ្លាប់ជាចោរ ដោយគ្មានការរើសអើងអ្វីឡើយ។ ធម៌ព្រះពុទ្ធបើកចំហចំពោះមនុស្សប្រុសស្រីគ្រប់រូប ដែលត្រៀមខ្លួនដើម្បីស្វែងយល់ និងប្រតិបត្តិតាម។ ព្រះពុទ្ធមិនមែនកើតមកជាព្រះពុទ្ធពីកំណើតនោះទេ គឺព្រះអង្គកើតមកជាមនុស្សមួយរូបប៉ុណ្ណោះ។ ព្រះអង្គបានយល់អំពីបញ្ហារបស់មនុស្ស ហើយព្រះអង្គក៏បានរកឃើញសច្ចធម៌ ដែលធ្វើឱ្យព្រះអង្គក្លាយទៅជាព្រះពុទ្ធ។ មនុស្សគ្រប់រូបមានសក្តានុពលនៅក្នុងខ្លួនរបស់គេ ដើម្បីក្លាយទៅជាព្រះពុទ្ធមួយព្រះអង្គបាន ប្រសិនបើគេមានការប្រាថ្នា និងការប្រឹងប្រែងគ្រប់គ្រាន់។ ព្រះពុទ្ធខុសប្លែកពីមេដឹកនាំសាសនាដទៃទៀត ត្រង់ព្រះអង្គមិនបានអះអាងថា ព្រះអង្គជាអ្វីដទៃក្រៅពីមនុស្ស និងមិនបានផ្តល់នូវតួនាទីពិសេសណាមួយក្នុងព្រះសាសនាដល់ខ្លួនព្រះអង្គឡើយ។ នៅក្នុងសាសនាគ្រិស្ត ព្រះយេស៊ូគ្រិស្តបានអះអាង ខ្លួនព្រះអង្គថាជាព្យាការីនៃសាសនាគ្រិស្ត និងជាបុត្រព្រះអាទិទេព។ គេត្រូវតែទទួលព្រះយេស៊ូគ្រិស្តថាជាបុត្រព្រះអាទិទេព បើពុំដូច្នោះទេ គេនឹងមិនអាចទទួលនូវការជួយសង្គ្រោះពីព្រះអង្គឡើយ។ នៅក្នុងសាសនាឥស្លាម ព្រះមូហាម៉ាត់អះអាងថា ព្រះអង្គជាព្យាការីចុងក្រោយរបស់ព្រះ បើបុគ្គលណាមិនទទួលស្គាល់ព្រះអង្គថា ជាព្យាការីចុងក្រោយទេ បុគ្គលនោះនឹងមិនអាចទទួលនូវការ

ជួយសង្គ្រោះបានឡើយ។

ចំណែកព្រះសម្មាសម្ពុទ្ធ លោកបានសំដែងថា ព្រះអង្គគឺជាមគ្គុទ្ទេសមួយអង្គប៉ុណ្ណោះ (មគ្គទាតា) មិនមែនជាអ្នកជួយសង្គ្រោះ(មោក្ខទាតា ឬ saviour) នោះទេ។ ដូច្នេះឋានៈរបស់មនុស្សក្នុងព្រះពុទ្ធសាសនា គឺឧត្តុង្គឧត្តមបំផុត។ មនុស្សជាម្ចាស់វាសនារបស់ខ្លួនគ្មានអំណាចខ្ពស់ណាមួយ ដែលគ្រប់គ្រងវាសនារបស់គេឡើយ។ ព្រះពុទ្ធបានសំដែងពីការទទួលខុសត្រូវរបស់បុគ្គលគ្រប់រូប ហើយជំរុញ និងលើកទឹកចិត្តឱ្យបុគ្គលម្នាក់ៗ អភិវឌ្ឍខ្លួនឯង ដើម្បីទទួលបាននូវវិមុត្តិ (ការរួចផុតចាកទុក្ខ) របស់ខ្លួន ពីព្រោះមនុស្សខ្លួនឯងមានអានុភាពរំដោះខ្លួនចេញពីចំណងគ្រប់ប្រការ ដោយសេចក្តីព្យាយាម និងបញ្ញាញ្ញាណរបស់ខ្លួន។ ដូច្នេះព្រះពុទ្ធសាសនាផ្តល់នូវសិទ្ធិមនុស្សពេញលេញ យុត្តិធម៌ និងការទទួលខុសត្រូវ ។ ព្រះពុទ្ធសំដែងថា "អ្នកត្រូវតែធ្វើកិច្ចការដើម្បីការរួចផុតចាកទុក្ខដោយខ្លួនឯង តថាគតគ្រាន់តែជាអ្នកបង្ហាញផ្លូវតែប៉ុណ្ណោះ **(តុម្ហេហិ កិច្ចំ អាតប្បំ អក្ខាតារោ តថាគតា)**"។

## ៦. សិទ្ធិ និងសមភាព

ជាប្រពៃណី សាសនាព្រាហ្មណ៍ហាមឃាត់ស្ត្រី ពួកវណ្ណៈទាប និងជនគេស្អប់ខ្ពើម មិនឱ្យប្រតិបត្តិសាសនា ដើម្បីបានរួចផុតចាកទុក្ខឡើយ។ ប៉ុន្តែព្រះពុទ្ធបានផ្តល់ការអនុញ្ញាតដល់ស្ត្រីឱ្យបានបួស និងប្រតិបត្តិព្រះធម៌របស់ព្រះអង្គ។ មានពួកវណ្ណៈទាប ជនត្រូវគេស្អប់ខ្ពើម និងជនឧក្រិដ្ឋជាច្រើនរូប បានបួសក្នុងព្រះពុទ្ធសាសនា ហើយបានសម្រេចបរមសុខគឺព្រះនិព្វានទៀតផង។ ជនទាំងនោះមានជាអាទិ៍ ឧបាលិ-ខ្មាន់ព្រះកេសព្រះរាជា, សុនីត-អ្នកបោសសម្រាម, សោបកៈ និងសុប្បិយៈ-ជនគេស្អប់ខ្ពើម, អង្គុលិមាល-ជាចោរព្រៃ ។ល។ ទោះបីឋានៈស្ត្រីនៃប្រទេសកាន់ព្រះពុទ្ធសាសនាក្នុងសម័យបច្ចុប្បន្ន ពុំទាន់បានខ្ពស់គួរជាទីពេញចិត្តនៅឡើយ ក៏ស្ត្រីទាំងនោះ កំពុងទទួលបាននូវសមភាព ការគោរព និងអំណាចខ្លាំងឡើងៗជាងពីសម័យមុន។ ឧត្តមភាពផ្តាច់មុខនៃបុរសបាន ចាប់ផ្តើមផ្តល់ឱកាសឱ្យស្ត្រីបានរួចរំដោះកាន់តែច្រើនឡើងៗ។ បម្លាស់ប្តូរនេះមានល្បឿនកើនឡើង ដោយបញ្ញាញាណពីកំណើតរបស់ស្ត្រី ដែលបង្ហាញថាពួកគេមានការទទួលខុសត្រូវមានសមត្ថភាព មានហេតុផលប្រកបដោយបញ្ញា។ បុព្វហេតុនេះហើយដែលបង្កឱ្យស្ត្រីលែងចាត់ទុកខ្លួនឯងថាឱនថយ និងបានបណ្តុះនូវចំណេះដឹង ស្តីពីភាពស្មើគ្នា

រវាងបុរស និងស្ត្រី ហើយឋានៈរបស់ស្ត្រីក៏កាន់តែមានកិត្តិយសឡើង។ ការជួយដ៏ចម្បងបំផុតរបស់ព្រះពុទ្ធ ចំពោះមនុស្សជាតិ គឺការបដិសេធនូវប្រព័ន្ធវណ្ណៈដែលធ្វើឱ្យមានភាពរើសអើងរវាងមនុស្សផ្អែកលើកំណើត ឬពូជសាសន៍។ ព្រះពុទ្ធបានបញ្ជាក់ច្បាស់ថាមនុស្សមានភាពស្មើគ្នានៅក្នុងដំណើរឆ្ពោះទៅកាន់ការសម្រេចនូវ សច្ចធម៌ដ៏ខ្ពង់ខ្ពស់បំផុត ។ ព្រះអង្គបង្រៀនថាមនុស្សទាំងឡាយក្លាយជាបុគ្គលខ្ពង់ខ្ពស់ ដោយសារសីលធម៌ និងការធ្វើទានប្រកបដោយសប្បុ-រសធម៌ ហើយគេក៏អាចក្លាយទៅជាជនថោកទាប ដោយសារអំពើអនាចារ និងសេចក្ដីកំណាញ់របស់គេ ពោលគឺមិនមែនដោយសារកំណើតឡើយ។ ដូច្នេះហើយពុទ្ធសាសនាបានផ្ដល់នូវសិទ្ធិការទទួលខុសត្រូវ យុត្តិធម៌ និងឧត្តមភាពដល់មនុស្សក្នុងសង្គម។

## ៧. មាគ៌ាបរិសុទ្ធ

ព្រះពុទ្ធសាសនាមិនមែនជាសាសនាក្នុងន័យដែលគេយល់ទូទៅនោះទេ ព្រះពុទ្ធសាស-នា គឺជាមាគ៌ាបរិសុទ្ធ សម្រាប់មនុស្សម្នាទាំងអស់ ដោយគ្មានការរើសអើង។ ទោះបីគេទទួលយកព្រះពុទ្ធ ឬក៏អត់វាមិនជាបញ្ហាទេ ព្រោះថាមហាករុណារបស់ព្រះពុទ្ធផ្សាយទៅស្មើគ្នាចំពោះសព្វសត្វទាំងអស់។ ព្រះពុទ្ធសាសនាបង្រៀនថា មូលហេតុចម្បងនៃបញ្ហា និងសេចក្ដីទុក្ខរបស់មនុស្ស កើតចេញពីចិត្តប្រកបដោយលោភៈ ទោសៈ និងមោហៈ របស់មនុស្ស។ អកុសលមូលនេះ វាបិទបាំងមិនឱ្យមនុស្សយល់នូវអ្វីត្រូវ អ្វីខុស ហើយគេក៏ប្រព្រឹត្តអំពើអកុសលផ្សេងៗ។ ប្រសិនបើមនុស្សមានចិត្តបរិសុទ្ធពោរពេញទៅដោយ មេត្តា ករុណា និងបញ្ញានោះ ការប្រព្រឹត្តិរបស់គេនឹងជាអំពើបរិសុទ្ធ និងជាកុសល។ ការណ៍ដែលគួរឱ្យសោកសៅគឺថា ចិត្តមនុស្សមិនមែនតែងតែបរិបូណ៌ដោយមេត្តា ករុណា និងបញ្ញានោះទេ វាតែងស្ដែងចេញនូវប្រតិកម្មអាក្រក់ចំពោះព្រឹត្តិការណ៍មិនជាទីពេញចិត្ត ដែលមកប៉ះផ្ទប់នឹងវា។ យល់ច្បាស់អំពីសភាវៈពិតនេះ ព្រះសម្មាសម្ពុទ្ធបានរំលឹកថា "ការមិនធ្វើបាបទាំងពួង ការចម្រើននូវសេចក្ដីល្អ ការធ្វើចិត្តឱ្យបរិសុទ្ធ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ"។

ទស្សនៈវិស័យ និងការអនុវត្តសិទ្ធិមនុស្សសព្វថ្ងៃ មិនសូវជាទូលំទូលាយដូចពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធនោះទេ ព្រោះថាសិទ្ធិមនុស្សមិនបានចែងឱ្យមនុស្សធ្វើចិត្តបរិសុទ្ធនោះឡើយ ពោលគឺសិទ្ធិមនុស្ស មិនបានស៊ីជំរៅដល់ផ្លូវចិត្តរបស់មនុស្សទេ។ ព្រះពុទ្ធបានពន្យល់ហេតុផល

នៃស្ថានភាពមនុស្ស ការរំលោភសិទ្ធិមនុស្ស និងអយុត្តិធម៌សង្គមថាមានឫសគល់ចេញពីការជាប់ជំពាក់ ឬការប្រកាន់មាំ (ឧបាទាន)។ ការជាប់ជំពាក់មាន៤ យ៉ាងគឺ : ការជាប់ជំពាក់ក្នុងវត្ថុកាម ការជាប់ជំពាក់ក្នុងទិដ្ឋិ ការជាប់ជំពាក់ក្នុងកិច្ចប្រតិបត្តិ និងប្រពៃណីទំនៀមទម្លាប់ និងការជាប់ជំពាក់នឹងតួខ្លួន (យល់ថាខ្លួនឯងសំខាន់ និងត្រូវទាំងអស់)។ ដើម្បីកំចាត់បង់នូវការជាប់ជំពាក់ទាំងនេះ ហើយធ្វើចិត្តឱ្យបរិសុទ្ធ ព្រះពុទ្ធបានបង្រៀននូវវិធីហ្វឹកហាត់៣យ៉ាងគឺ: **សីល សមាធិ** និង **បញ្ញា**។

## ៨. វិធីហ្វឹកហាត់៣យ៉ាង

គោលដៅចម្បងរបស់ព្រះពុទ្ធសាសនា គឺការសម្រេចនូវបរមសុខព្រះនិព្វានតាមរយៈការប្រតិបត្តិមាគ៌ាដ៏បរិសុទ្ធ។ គោលដៅនោះមិនអាចសម្រេចដោយងាយស្រួលទេ ប៉ុន្តែគេអាចសម្រេចបានដោយការបដិបត្តិនូវមាគ៌ានេះតាមលំដាប់លំដោយ។ ព្រះពុទ្ធបានសម្តែងថា "ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលថា ការសម្រេចនូវលោកុត្តរៈបញ្ញាកើតឡើងដោយភ្លាមនោះៗទេ ប៉ុន្តែវាកើតឡើងដោយការហ្វឹកហាត់ជាលំដាប់លំដោយ ការបដិបត្តិជាលំដាប់លំដោយ និងការអប់រំជាលំដាប់លំដោយ"។

**សីល** គឺជាមូលដ្ឋានគ្រឹះនៃការហ្វឹកហាត់រាប់បញ្ចូលទាំងគុណធម៌ទាំងឡាយ និងការធ្វើកាយ វាចា ចិត្ត ឱ្យបរិសុទ្ធតាមរយៈការវៀរចាកនូវអំពើអកុសលទាំងពួង។ សីល៥ ឬបញ្ចសីល គឺជាក្រមសីលធម៌សម្រាប់គ្រហស្ថបដិបត្តិ។ មនុស្សជាសត្វសង្គម ដែលមានលក្ខណៈសីលធម៌ជាប់ទាក់ទិនទៅនឹងសង្គមដែលគេរស់នៅ ដូច្នេះអ្វីដែលគេធ្វើ មានឥទ្ធិពលមិនត្រឹមតែចំពោះខ្លួនគេប៉ុណ្ណោះទេ តែចំពោះសង្គមផងដែរ។

ដើម្បីធ្វើឱ្យសកម្មភាពមនុស្សមានឥទ្ធិពលល្អដល់សង្គម ការប្រតិបត្តិនូវសីល៥ ពិតជាឱ្យផលតាមគោលបំណងពុំខានឡើយ។ សីល ឬសិក្ខាបទទាំង៥ នោះគឺ :

១. វៀរចាកការបៀតបៀន និងការសម្លាប់សត្វ

២. វៀរចាកការលួចទ្រព្យគេ

៣. វៀរចាកការប្រព្រឹត្តិខុសក្នុងកាម

៤. វៀរចាកការនិយាយកុហក

៥. វៀរចាកការសេពនូវទឹកស្រវឹង និងគ្រឿងញៀនផ្សេងៗ។

សិក្ខាបទទាំងនេះមានមូលដ្ឋានគ្រឹះចេញពីមេត្តា និងករុណា វានឹងបង្កើតឱ្យជីវិតមានតម្លៃ មិនត្រឹមតែរវាងមនុស្សប៉ុណ្ណោះទេ ប៉ុន្តែរវាងសព្វសត្វទាំងអស់ផងដែរ។

**សមាធិ** គឺការធ្វើចិត្តឱ្យបរិសុទ្ធ។ តាមរយៈការបដិបត្តិនូវសមាធិ គេអាចរក្សាបាននូវសីលធម៌កម្រិតខ្ពស់។ ការអប់រំចិត្ត គឺជាកត្តាសំខាន់ណាស់ បទល្មើសផ្សេងៗ អំពើហឹង្សា ការរំលោភបំពាន កើតឡើងច្រើនហួសប្រមាណ ព្រោះតែយើងមិនបានអប់រំចិត្តនោះឯង។ ដូច្នេះការអនុវត្តសមាធិ មានសារៈសំខាន់ណាស់ដើម្បីឱ្យជីវិតរស់ក្នុងភាពរុងរឿងក្នុងសង្គម។

**បញ្ញា** គឺការយល់ត្រឹមត្រូវអំពីជីវិតថា ជាសភាវៈមិនទៀងទាត់ ប្រកបដោយសេចក្តីទុក្ខលំបាក និងគ្មានអត្តាតួខ្លួន។ តាមរយៈបញ្ញា យើងអាចកំចាត់ឫសគល់នៃភាពមិនបរិសុទ្ធដែលត្រាំនៅក្នុងសន្តានចិត្តរបស់យើង វាគឺជាការជំរះចិត្តឱ្យបរិសុទ្ធទាំងស្រុង។ នៅពេលចិត្តបរិសុទ្ធប្រាសចាកនូវអវិជ្ជា យើងអាចសម្រេចនូវសច្ចធម៌ និងទទួលបាននូវសេចក្តីសុខក្នុងព្រះនិព្វាន ។

## ៩. បញ្ញានិងសីល

ពិតណាស់ បញ្ញាគឺជាកត្តាសំខាន់ ប៉ុន្តែសីលសំខាន់ជាងបញ្ញាទៅទៀត ព្រោះថាបញ្ញាដែលប្រាសចាកសីលធម៌នឹងផ្តល់នូវគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ។ បញ្ញាប្រៀបបាននឹងដាវក្នុងដៃមនុស្ស បើវាស្ថិតនៅក្នុងដៃមនុស្សមានសីល គេអាចប្រើវាការពារជីវិតឱ្យផុតពីគ្រោះថ្នាក់បាន ប៉ុន្តែបើស្ថិតនៅក្នុងដៃមនុស្សគ្មានសីលវិញនោះ គេអាចប្រើវាសម្រាប់ប្រហារជីវិត។ អាស្រ័យហេតុនេះ សីលមានសារៈសំខាន់ជាងបញ្ញា។ ហេតុផលដែលព្រះពុទ្ធផ្តល់សារៈសំខាន់ដល់សីលជាងបញ្ញានោះ ព្រោះថាការប្រើប្រាស់បញ្ញាអាស្រ័យនឹងសីលរបស់មនុស្ស។ បញ្ញាដែលគ្មានសីលធម៌ គឺគ្មានតម្លៃនោះទេ។ សព្វថ្ងៃ យើងឃើញអយុត្តិធម៌ បទល្មើស អំពើហឹង្សាកើតឡើងដោយសារកង្វះសីលធម៌។ ព្រះពុទ្ធសំដែងថា សីលគឺគ្មានអ្វីប្រៀបផ្ទឹមស្មើទេក្នុងលោកនេះ "សីលគឺជាការចាប់ផ្តើម សីលជាទីពឹង សីលជាមាតានៃសេចក្តីល្អទាំងពួង សីលជាចម្បងនៃកុសលធម៌ទាំងឡាយ ដូច្នេះចូរចម្រើននូវសីលរបស់ខ្លួនឱ្យបរិសុទ្ធ"។

## ១០. បញ្ញានិងករុណា

បុគ្គលខ្លះនិយាយថា បញ្ញាគឺជាមូលដ្ឋានគ្រឹះពុទ្ធសាសនា អ្នកខ្លះទៀតថាករុណាជាមូលដ្ឋានគ្រឹះ។ តាមពិត ប្រសិនបើយើងសិក្សាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធឱ្យបានគ្រប់ជ្រុងជ្រោយ យើងនឹងឃើញថា បុគ្គលត្រូវតែចំរើននូវគុណធម៌ចាំបាច់ទាំងពីរគឺៈ ករុណា និងបញ្ញាឱ្យបានបរិបូរណ៍ស្មើគ្នា។ ករុណាគឺជាសេចក្ដីស្រឡាញ់ ចិត្តសប្បុរស ចិត្តទន់ភ្លន់ សេចក្ដីសន្ដោសដែលជាគុណធម៌ដ៏ថ្លៃថ្លា ជាគុណធម៌ដែលកើតចេញពីបេះដូង ចំណែកឯបញ្ញាតំណាងឱ្យផ្នែកការយល់ដឹង ឬជាគុណធម៌នៃគំនិត។ ប្រសិនបើបុគ្គលចំរើនតែគុណធម៌ផ្នែកខាងមនោសញ្ចេតនា និងព្រងើយកន្ដើយគុណធម៌ខាងបញ្ញាស្មារតី គេអាចក្លាយជាបុគ្គលល្ងង់ខ្លៅតែចិត្តល្អ (a good-hearted fool) ខណៈដែលបុគ្គលចំរើនតែផ្នែកបញ្ញាស្មារតី ដោយព្រងើយកន្ដើយផ្នែកមនោសញ្ចេតនា គេអាចក្លាយជាបញ្ញវន្តចិត្តខ្វះ (a hard-hearted intellectual) ដែលគ្មានការអាណិតអាសូរចំពោះអ្នកដទៃ។ ដូច្នេះបុគ្គលត្រូវតែចំរើនគុណធម៌ទាំងពីរនេះឱ្យបរិបូរណ៍ស្មើគ្នា។ នៅក្នុងព្រះពុទ្ធសាសនាមហាយាន ព្រះពោធិសត្វ គឺជាអ្នកបរិបូរដោយកម្លាំងពីរយ៉ាងគឺ ករុណា និងបញ្ញា។ ករុណាគ្រប់គ្រងការប្រព្រឹត្តិចំពោះមនុស្សម្នាទូទៅ ហើយបញ្ញាគ្រប់គ្រងនូវអាកប្បកិរិយារបស់គេចំពោះសច្ចធម៌។ ដូច្នេះ ការចំរើនទាំងបញ្ញា និងករុណាមានសារៈសំខាន់ណាស់ ព្រោះថាបញ្ញា និងករុណាគឺជាមុខទាំងពីរនៃសច្ចធម៌។ បើគ្មានបញ្ញាក៏គ្មានករុណា បើគ្មានករុណា ក៏គ្មានបញ្ញាដែរ។ បញ្ញាវាមិនសំដៅលើចំណេះវាចារនោះទេ វាជាចំណេះដឹងពីកំណើត វីការចេះដឹងតាមរយៈបទពិសោធន៍ ដែលគេអាចហៅថាអតិសេដ្ឋបញ្ញា ជាបញ្ញាមួយដែលដឹងអំពីបញ្ហាទូលំទូលាយ។ យើងនិយាយថា បញ្ញា និងករុណាជារឿងពីរផ្សេងគ្នា តែតាមពិតវាមិនមែនជារឿងផ្សេងគ្នាឡើយ ព្រោះថាបញ្ញាគឺករុណា ហើយករុណាជាបញ្ញា។ ដូច្នេះហើយទើបគេនិយាយថា "អ្នកមានបញ្ញាដ៏អស្ចារ្យនោះ គឺពិតជាមានករុណា។ ករុណាកើតមកពីបញ្ញា បញ្ញាគឺជាករុណា"។ នេះគឺជាទ្រឹស្ដីសំខាន់របស់មហាយាន។

## ១១. ច្បាប់កម្មផល

ក្នុងភាវរូបទាំងឡាយមានក្រឹត្យក្រមមួយ ដែលជាចលនា ឬសកម្មភាពនៃសរីរាង្គ មានរដូវផ្លាស់ប្ដូរតាមលំដាប់ជាប្រក្រតី ដូចជាគ្រាប់ពូជដុះលូតលាស់ទៅជារុក្ខជាតិ រុក្ខជាតិផ្ដល់

ផ្លែផ្កា ហើយផ្លែផ្កាផ្តល់នូវគ្រាប់ពូជវិញ។ ព្រះពុទ្ធសាសនាហៅក្រឹត្យក្រមនេះថា "និយាម" គឺជាច្បាប់ដែលបង្កើតនូវក្រឹត្យក្រមលំដាប់លំដោយ។ ដូចគ្នានេះដែរ នៅក្នុងសង្គមមនុស្សមានក្រឹត្យក្រមសីលធម៌។ តើក្រឹត្យក្រមសីលធម៌កើតឡើងដូចម្តេច? ហើយវាតាំងនៅដូចម្តេច? អ្នកដែលជឿលើព្រះអាទិទេពបង្កើតលោក ក្រឹត្យក្រមសីលធម៌តាំងនៅដោយអំណាចព្រះអាទិទេព ពោលគឺព្រះអង្គជាអ្នកបង្កើត និងជាអ្នកឃុំគ្រងក្រឹត្យក្រមសីលធម៌ និងក្រឹត្យក្រមអរូបីទាំងអស់។ យោងតាមព្រះពុទ្ធអង្គ ក្រឹត្យក្រមសីលធម៌ក្នុងភពចក្រវាឡឃុំគ្រងដោយកម្មនិយាម មិនមែនឃុំគ្រងដោយព្រះអាទិទេពទេ។ ប្រសិនបើមនុស្សធ្វើអំពើល្អ ក្រឹត្យក្រមសីលធម៌ក៏ល្អ ប្រសិនបើមនុស្សធ្វើអាក្រក់ ក្រឹត្យក្រមសីលធម៌ក៏អាក្រក់។ ផលកើតឡើងតពីកម្ម ដូចជាយប់កើតឡើងតពីថ្ងៃ។ យោងតាមទ្រឹស្តីហេតុបច្ច័យ (បដិច្ចសមុប្បាទ) គ្មានបាតុភូត ឬព្រឹត្តិការណ៍កើតឡើងដោយសារហេតុតែមួយនោះទេ ពោលគឺមានហេតុបច្ច័យច្រើនតគ្នា។

## ១២. អសមភាព

យោងតាមព្រះពុទ្ធសាសនា អសមភាពដែលយើងឃើញនៅក្នុងពិភពលោកមិនមែនសុទ្ធតែកើតឡើងអាស្រ័យដោយផៅពង្ស បរិយាកាស ធម្មជាតិ និងអាហារនោះទេ ប៉ុន្តែវាអា-ស្រ័យដោយផលវិបាករបស់កម្មផងដែរ។ គេអាចនិយាយម្យ៉ាងទៀតថា វាជាផលវិបាកដែលយើងទទួលពីកម្មក្នុងអតីតកាល និងកម្មក្នុងបច្ចុប្បន្ន។ យើងត្រូវទទួលខុសត្រូវ ចំពោះសេចក្តីសុខ-ទុក្ខរបស់យើង។ យើងបង្កើតឋានសួគ៌ និងឋាននរកសម្រាប់ខ្លួនយើង។ យើងគឺជាស្ថាបត្យ-ករនៃវាសនារបស់យើង ។ ព្រះពុទ្ធសំដែងថា "សត្វទាំងឡាយមានកម្មជាម្ចាស់ កម្មជាផៅពង្ស កម្មជាពូជ កម្មជាញាតិ កម្មជាទីពឹង កម្មបែងចែកសត្វឱ្យមានខ្ពស់ទាប"។ និយាយអោយចំកម្មមានន័យថា សកម្មភាពដែលព្រះពុទ្ធអង្គកំណត់ថាវាកើតមកពីឆន្ទៈផ្លូវចិត្ត "ចេតនា"។ ព្រះអង្គទ្រង់សំដែងថា "ម្នាលភិក្ខុទាំងឡាយ សេចក្តីប៉ងប្រាថ្នាគឺជាកម្ម។ បើមានការប៉ងប្រាថ្នាហើយសកម្មភាពនឹងកើតមានតាមរយៈ រូបរាង កាយ វាចារ រឺ ចិត្ត"។

គ្រប់សកម្មភាពដែលបានបដិបត្តិដោយចេត្តនាល្អគឺជាកុសលកម្ម ប៉ុន្តែបើសកម្មភាពដោយចេត្តនាមិនល្អ នោះហៅថាអកុសលកម្ម។ ដូច្នេះវាមិនមែនជារឿងរាវខាងក្រៅ រឺជាតំរូវការដែលអាចមើលឃើញនោះឡើយ ប៉ុន្តែវាជាចលករ រឺចេតនាដែលទាក់ទងទៅនឹងការ

គិតគូរ ការនិយាយស្តី រឺសកម្មភាពដែលកំពុងធ្វើ។ អំពើដែលគ្មានបំណង រឺខ្វះនូវចេតនាគឺមិនអាចហៅថាកម្មឡើយ។ យោងតាមច្បាប់កម្មផល កម្មដែលធ្វើឡើងដោយការតាំង ចិត្តពិតប្រាកដរមែងតែងទទួលនូវលទ្ធផលរបស់វា ទោះជាសេចក្តីរីករាយ រឺជាទុកសោកសៅក៏ដោយ គឺត្រូវតែមាន ទៅតាមកំរិតនៃចេតនានោះ។

## ១៣. សេរីភាពគំនិត

សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១៨ ចែងថាមនុស្សគ្រប់រូបមានសិទ្ធិទទួលនូវសេរីភាពខាងគំនិត សម្បជញ្ញៈ និងសាសនា។ តាំងពីដើមមក ព្រះពុទ្ធសាសនាបានទទួលស្គាល់នូវសិទ្ធិទទួលបាននូវសេរីភាពគំនិត សម្បជញ្ញៈ និងសាសនា។ សេរីភាពដែលព្រះពុទ្ធបានអនុញ្ញាត គឺមិនធ្លាប់ឮពីមុនមកនៅក្នុងប្រវត្តិសាសនាទាំងឡាយ។ ធម៌ព្រះពុទ្ធបើកចំហដល់មនុស្សគ្រប់រូបដោយគ្មានការរើសអើង ព្រោះវណ្ណៈ ឋានៈ ឬពណ៌សម្បុរឡើយ ហើយមិនបង្ខំឱ្យមនុស្សទទួលយកដោយងងិតងងុលនោះដែរ គឺព្រះធម៌អនុញ្ញាតឱ្យមនុស្សទាំងឡាយចូលមកមើល (ឯហិបស្សិកោ) ដើម្បីពិនិត្យនូវសច្ចភាព និងសុពលភាពមុននិងទទួលយក។ ទោះណាជាព្រះពុទ្ធបានពោលថា នេះជាផ្លូវតែមួយគត់ដើម្បីភាពបរិសុទ្ធិ (ឯកោ មគ្គោ វិសុទ្ធិយា) ក៏ដោយ ប្រសិនបើការអះអាងនេះត្រូវបានរកឃើញថាគ្មានហេតុផល គេអាចស្វែងរកនូវសច្ចធម៌នៅកន្លែងដទៃទៀតបាន។ លទ្ធិដែលអនុញ្ញាតឱ្យមនុស្សពិនិត្យពិច័យនូវសច្ចភាពរបស់ខ្លួនគឺពិតជាឈរលើគោលការណ៍សេរីភាពគំនិតយ៉ាងជាក់ស្តែង។ ធម៌ព្រះពុទ្ធគប្បីស្វែងយល់ដោយបុគ្គលគ្រប់រូបជាបណ្ឌិត (បច្ចត្តំ វេទិតព្វោ វិញ្ញូហិ) ការស្វែងយល់មិនអាចប្រព្រឹត្តទៅបានទេបើគ្មានសេរីភាពគំនិត (freedom of thought)។

សម្បជញ្ញៈ គឺជាសីលដែលអាចដឹងត្រូវ និងខុស ដែលពុទ្ធសាសនាបានចំរើនរួចមកហើយ។ សម្បជញ្ញៈ ដើរតួក្នុងការសំរេចលើតំលៃនៃសកម្មភាព។ ពុទ្ធសាសនាវាស់វែងកំណត់តំលៃសកម្មភាពតាមរយៈលទ្ធផលរបស់វា។ ដូច្នេះហើយ មនុស្សម្នាក់ៗត្រូវតែនិយាយតាមសម្បជញ្ញៈរបស់ខ្លួនអំពីហេតុបច្ច័យនានាចេញពីសកម្មភាពរបស់ខ្លួន។ ព្រះពុទ្ធបានប្រៀនប្រដៅរ៉ាហុល "ចូរធ្វើសកម្មភាពទាំងឡាយណាដែលគួរនាំនូវអំពើរល្អដែលមិន មានលទ្ធផលអាក្រក់ប៉ះពាល់ដល់ខ្លួនឯងនិងអ្នកដទៃ"។

ពាក្យប្រៀនប្រដៅដ៏សំខាន់បំផុតស្តីពី សេរីភាពគំនិត និងសម្បជញ្ញៈគឺមាននៅក្នុងពុទ្ធឱវាទចំពោះអ្នកស្រុកកាលាមៈ "ម្នាលកាលាមៈ! ចូរអ្នកកុំជឿដោយឮគេនិយាយ ដោយសារប្រពៃណី តាមពាក្យចចាមអារាម ឬដោយហេតុថា បុគ្គលគួរឱ្យជឿទុកចិត្ត ឬក៏ដោយសារការគោរពចំពោះគ្រូខ្លួន។ ម្នាលកាលាមៈ! នៅពេលអ្នកដឹងច្បាស់ដោយខ្លួនឯងថា ធម៌នេះឥតប្រយោជន៍ គួរឱ្យតិះទៀន និងដឹកនាំទៅរកការបាត់បង់ និងសេចក្តីទុក្ខសោក អ្នកគួរតែបោះបង់ធម៌នោះចោល។ នៅពេលអ្នកដឹងច្បាស់ដោយខ្លួនឯងថា ធម៌នេះមានប្រយោជន៍មិនគួរដល់ការតិះទៀន និងដឹកនាំទៅរកផលប្រយោជន៍ និងសេចក្តីសុខ អ្នកគួរតែទទួលយក និងបដិ-បត្តិតាម"។

## ១៤. សេរីភាពសាសនា

សិទ្ធិទទួលបានសេរីភាពសាសនា និងការសន្តោស ដែលព្រះពុទ្ធបានអនុញ្ញាត គឺជាការភ្ញាក់ផ្អើលចំពោះអ្នកសិក្សាអំពីប្រវត្តិសាសនា។ ព្រះពុទ្ធបានទូន្មានសាវ័ករបស់ព្រះអង្គឱ្យគោរពគ្រប់និកាយសាសនាទាំងអស់។ ជាឧទាហរណ៍ គហបតីឧបាលី ដែលជាសាវ័កដ៏ខ្ពង់ខ្ពស់បរិបូណ៌ដោយទ្រព្យធន និងមានកេរ្តិ៍ឈ្មោះល្បីរបស់និគន្ថនាថបុត ក្រោយពីបានជួបសន្ទនាជាមួយព្រះពុទ្ធមានជំនឿមុតមាំថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធត្រឹមត្រូវ ហើយពាក្យប្រៀនប្រដៅរបស់គ្រូខ្លួនមិនត្រឹមត្រូវ។ នៅពេលនោះគាត់បានស្នើព្រះពុទ្ធឱ្យទទួលយកគាត់ជាឧបា-សកមួយរូប ប៉ុន្តែព្រះពុទ្ធស្នើឱ្យគាត់ពិចារណាឡើងវិញ កុំធ្វើការសម្រេចចិត្តប្រញាប់ប្រញាល់ "ព្រោះថា ការពិចារណាដោយប្រុងប្រយ័ត ជាគុណប្រយោជន៍សម្រាប់មនុស្សដែលមានកេរ្តិ៍ឈ្មោះដូចអ្នក"។ ឧបាលីកាន់តែជឿជាក់លើព្រះពុទ្ធ ហើយពោលថា "ទូលព្រះបង្គំមិនដែលជួបមេសាសនាណាដូចព្រះអង្គឡើយ ព្រោះថាព្រះអង្គមិនត្រឹមតែមិនព្យាយាមអូសទាញទូលព្រះបង្គំឱ្យចូលក្នុងសាសនា នៅពេលឧបាលីស្នើសុំជាគម្រប់បីដងព្រះពុទ្ធទ្រង់យល់ព្រម តែស្នើសុំឧបាលីឱ្យបន្តការគាំទ្រ និងគោរពដល់មេសាសនារបស់គាត់មុន ដូចធ្លាប់បានធ្វើ។ សេនាបតីសីហៈ នៃទីក្រុងវេសាលីដែលជាសាវ័ករបស់ និគន្ថនាថបុតមួយរូបដែរនោះ ក្រោយពីបានជួបសន្ទនាជាមួយព្រះពុទ្ធបានប្រកាសខ្លួនជាសាវ័ករបស់ព្រះពុទ្ធ។ ព្រះពុទ្ធព្រមទាំងទទួលគាត់ក្នុងលក្ខខណ្ឌតែថែមទាំងឱ្យទូលព្រះបង្គំពិចារណាឡើងវិញ ដោយប្រុងប្រយ័ត្នមុននឹងសម្រេចចិត្ត

ចូលកាន់សាសនាព្រះអង្គ ប្រសិនបើទូលព្រះបង្គំទៅសុំចូលសាសនាដទៃ មេដឹកនាំសាសនានោះ នឹងឱ្យគេរៀបចំក្បួនដង្ហែយ៉ាងឱឡារិកអធិកអធម ហើយពោលថា "ឧបាលីពីដើមកាន់សាសនាដទៃ តែឥឡូវនេះចូលមកកាន់សាសនាយើងហើយ"។ នៅពេលឧបាលីស្នើសុំជាគំរប់បីដង ព្រះពុទ្ធទ្រង់យល់ព្រមតែស្នើសុំឧបាលីឱ្យបន្តការគាំទ្រ និងគោរពដល់មេសាសនារបស់គាត់មុន ដូចធ្លាប់បានធ្វើ។ ករណីទាំងពីរនេះ បង្ហាញយ៉ាងប្រត្យក្សថា ព្រះពុទ្ធសាសនាមានការបារម្ភអំពីឥទ្ធិពលសាសនាក្នុងសង្គម ហើយយល់ឃើញថា សាសនាមិនគួរប្រើជាកម្មវត្ថុបំបែកបំបាក់នោះទេ ប៉ុន្តែគួរជាកម្លាំងបង្រួបបង្រួម សម្រាប់លើកស្ទួយបញ្ញាស្មារតីសេចក្ដីសុខ និងសុខុមាលភាពមនុស្សទូទៅ។ ដូច្នេះ មិនគួរឱ្យមានជម្លោះណាមួយ ក្នុងនាមសាសនា ឬដោយសារសាសនានោះទេ។ នៅសតវត្សទី៣មុនគ្រិស្តសករាជ ព្រះបាទអសោកមហារាជ ដែលជាពុទ្ធសាសនិកមួយអង្គ បានគោរព និងគាំទ្រសាសនាទាំងអស់ នៅក្នុងមហាអាណាចក្ររបស់ព្រះអង្គ។ ដោយមានបំណងចង់ឱ្យប្រជារាស្ត្ររបស់ព្រះអង្គ ដើរតាមគំរូដ៏ថ្លៃថ្លានៃការសន្ដោស និងការយោគយល់នេះ ព្រះអង្គបានឱ្យគេចារិកនូវព្រះរាជបញ្ញត្តិ របស់ព្រះអង្គលើផែនថ្មដែលគេអាចអានបានសព្វថ្ងៃ។ ព្រះមហារាជបានប្រកាសថា "ជនណាមិនគោរពសាសនាអ្នកដទៃ មិនគោរពសាសនារបស់ខ្លួន ជនណាគោរពសាសនាអ្នកដទៃ ជននោះគោរពសាសនារបស់ខ្លួន"។

សព្វថ្ងៃនេះ យើងកំពុងធ្វើការជាមួយសាសនាផ្សេងៗ ក្នុងគោលបំណងដើម្បីរួមរស់ជាមួយគ្នាប្រកបដោយសុខដុមរមនា ដូច្នេះយើងគួរតែអនុវត្តតាមស្មារតីប្រកបដោយសមានចិត្ត ការយោគយល់និងសេចក្ដីសន្ដោសខាងលើ។ ស្មារតីនៃការសន្ដោស និងការយោគយល់បានក្លាយជាគោលប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនបំផុត ក្នុងវប្បធម៌ប្រពៃណីព្រះពុទ្ធសាសនា។

## ១៥. ព្រហ្មវិហារធម៌

ព្រះពុទ្ធសាសនាបង្រៀនឱ្យមនុស្សប្រតិបត្តិនូវគុណធម៌ដ៏ប្រសើរបួនយ៉ាង ដែលហៅថា "ព្រហ្មវិហារធម៌" ចំពោះមនុស្សសត្វទូទៅ ដោយគ្មានភាពរើសអើងផ្អែកលើ វណ្ណៈ ភេទ ពណ៌សម្បុរ សាសនា ឬពូជសាសន៍ឡើយ។ ព្រហ្មវិហារធម៌បួននោះគឺ :

- **មេត្តា** សេចក្ដីស្រលាញ់គ្មានព្រំដែន និងគ្មានលក្ខខណ្ឌ។ ប្រសិនបើសេចក្ដីស្រឡាញ់ជាប់ជំពាក់ដោយផលប្រយោជន៍ផ្ទាល់ខ្លួន ឬការប្រកាន់ណាមួយនោះ វាមិនមែនជា

មេត្តានោះទេ។ មេត្តាពិតប្រាកដ គឺការផ្សព្វផ្សាយនូវសេចក្តីស្រឡាញ់ចំពោះមនុស្សសត្វទាំងអស់ដោយគ្មានព្រំដែន ដោយគ្មានរំពឹងគុណស្រ័យ ឬការធ្វើតបវិញ។

- **ករុណា** សេចក្តីអាណិតអាសូរដ៏បរិសុទ្ធ គ្មានព្រំដែន គ្មានលក្ខខណ្ឌចំពោះមនុស្សសត្វដែលកំពុងរងទុក្ខវេទនា។ បុគ្គលដែលប្រតិបត្តិនូវករុណា មានជីវិតរស់នៅមិនដើម្បីខ្លួនឯងទេ គឺដើម្បីអ្នកដទៃ។

- **មុទិតា** សេចក្តីត្រេកអរដ៏បរិសុទ្ធគ្មានព្រំដែន គ្មានលក្ខខណ្ឌ ត្រេកអរចំពោះការជោគជ័យ និងសេចក្តីសុខរបស់អ្នកដទៃ។

- **ឧបេក្ខា** ការតាំងចិត្តជាកណ្តាលមិនលំអៀង ចំពោះហេតុការណ៍ផ្សេងៗ។ ឧបេក្ខាជាគុណធម៌ ដែលពិបាកប្រតិបត្តិបំផុត ព្រោះថាការមិនញាប់ញ័រចំពោះលោកធម៌ទាំងឡាយ គឺអាចប្រព្រឹត្តទៅបានតែនៅក្នុងប៉ុណ្ណោះ។ ប្រសិនបើមនុស្សទាំងឡាយ ប្រតិបត្តិតាមគុណធម៌ដ៏ប្រសើរបួនយ៉ាងឱ្យបានខ្ជាប់ខ្ជួននោះ អំពើហិង្សា ការរំលោភសិទ្ធិមនុស្ស អំពើអយុត្តិធម៌មិនអាចកើតមានក្នុងសង្គមបានទេ។

## ១៦. ជៀសវាងអគតិ

គេទទួលស្គាល់ថា អំពើអយុត្តិធម៌ ទោះតិចក្តីច្រើនក្តី កើតមាននៅគ្រប់សង្គម និងប្រជាជាតិទាំងអស់។ យោងតាមព្រះពុទ្ធសាសនា អំពើអកុសលបែបនេះកើតឡើងអាស្រ័យដោយមនុស្សមានតណ្ហា ឧបាទាន ទិដ្ឋិ និងមានៈ នៅក្នុងសណ្តាន។ ម្យ៉ាងទៀតព្រះពុទ្ធសាសនាក៏បានបង្ហាញហេតុ៤យ៉ាង ដែលនាំឱ្យអ្នកកាន់យុត្តិធម៌មានភាពលំអៀង ដែលមិនអាចឱ្យប្រើយុត្តិធម៌បានត្រឹមត្រូវ។ ក្នុងព្រះពុទ្ធសាសនា ហេតុដែលនាំឱ្យលំអៀងនោះ ហៅថា "អគតិ៤យ៉ាង" គឺ :

- **ឆន្ទាគតិ** សេចក្តីលំអៀងព្រោះស្រឡាញ់។ អ្នកកាន់យុត្តិធម៌ នឹងមិនអាចប្រើយុត្តិធម៌បានទេ កាលណាបើមានសេចក្តីស្រឡាញ់ ការពេញចិត្តនោះ។

- **ទោសាគតិ** សេចក្តីលំអៀងព្រោះក្រោធខឹង ព្រោះស្អប់។ បើបុគ្គលមានកំហឹងមានសម្អប់ក្នុងខ្លួន យុត្តិធម៌មិនអាចកើតមានបានទេ។

- **ភយាគតិ** សេចក្តីលំអៀងព្រោះភ័យខ្លាច។ អ្នកកាន់យុត្តិធម៌ កាលណាបើមាន

សេចក្តីភ័យខ្លាចថា បើអញធ្វើត្រឹមត្រូវ ធ្វើឱ្យមានយុត្តិធម៌ អ្នកនោះនឹងបៀតបៀនអញ ចងគំនុំគុំគួននឹងអញ នឹងបក្សពួករបស់អញ ឬក្រុមគ្រួសារអញ។

- **មោហាគតិ** សេចក្តីលំអៀងព្រោះវង្វេង ព្រោះល្ងង់។ កាលណាបើបុគ្គលមិនដឹងការពិត គ្មានព័ត៌មានជាក់លាក់ គេមិនអាចប្រព្រឹត្តយុត្តិធម៌បានឡើយ។

## ១៧. សេចក្តីសន្និដ្ឋាន

យុត្តិធម៌សង្គម គឺការផ្តល់នូវសមភាព សេចក្តីថ្លៃថ្នូរ និងផលប្រយោជន៍ស្មើគ្នាដល់បុគ្គល ឬក្រុមមនុស្សនៅក្នុងសង្គម។ មនុស្សគ្រប់រូប តែងចង់បានយុត្តិធម៌ ចង់រស់ក្នុងសង្គមដែលមានយុត្តិធម៌ ប៉ុន្តែមនុស្សភាគច្រើនពុំសូវទទួលបានដូចបំណងទេ។ ព្រះសម្មាសម្ពុទ្ធបានលើកតម្កើងតម្លៃសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូប គ្រប់ឋានៈ និងវណ្ណៈសង្គម។ មនុស្សកើតមកមានសិទ្ធិសេរីភាពស្មើគ្នា គេមានសិទ្ធិជឿជំនឿសាសនារៀងៗខ្លួន។ នៅក្នុងសាសនារបស់ព្រះអង្គ ព្រះសម្មាសម្ពុទ្ធមិនត្រឹមតែអនុញ្ញាតឱ្យស្ត្រីគោរពប្រតិបត្តិពាក្យប្រៀនប្រដៅរបស់ព្រះអង្គប៉ុណ្ណោះទេ តែថែមទាំងឱ្យស្ត្រីចូលបួសជាភិក្ខុនី ស្មើភាពដូចបុរសដែរ។

ការប្រតិបត្តិសីល៥ របស់ព្រះពុទ្ធសាសនា នឹងធ្វើឱ្យមានយុត្តិធម៌សង្គមពិតប្រាកដ ព្រោះថា មនុស្សរស់នៅក្នុងសង្គម បានផ្តល់សិទ្ធិដល់គ្នានឹងគ្នាឱ្យរស់រានមានជីវិតដោយសុខស្រួល ទ្រព្យសម្បត្តិផ្ទាល់ខ្លួនក៏គង់វង្ស ស្ថិតស្ថេរ ក្រុមគ្រួសារក៏មានសុខសុវត្ថិភាព មនុស្សនិយាយតែពាក្យពិត ពាក្យត្រង់ មនុស្សមិនប្រព្រឹត្តគ្រឿងស្រវឹង គ្រឿងញៀន ដែលធ្វើឱ្យសង្គមដល់នូវភាពវឹកវរផ្សេងៗ។

ការចម្រើននូវព្រហ្មវិហារធម៌បួន ធ្វើឱ្យមនុស្សមានការស្រឡាញ់រាប់រកគ្នាស្និទ្ធស្នាល មានការអាណិតអាសូរគ្នា ចេះជួយទុក្ខធុរៈគ្នាទៅវិញទៅមក និងមិនប្រកាន់បក្សពួក។ កាលណាមនុស្សមានសេចក្តីស្រឡាញ់ អាណិតអាសូរគ្នា គេមិនអាចប្រព្រឹត្តអំពើហិង្សា ការរំលោភបំពាន ឬអំពើអយុត្តិធម៌ដល់គ្នាឡើយ។ នៅពេលដែលបុគ្គលវៀរចាកអគតិបួនយ៉ាងដូចបានរៀបរាប់ខាងលើ អយុត្តិធម៌សង្គមពិតជាមិនអាចកើតឡើងបានឡើយ។ ដូច្នេះការប្រតិបត្តិតាមគោលការណ៍ព្រះពុទ្ធសាសនានឹងនាំមកនូវសិទ្ធិ សេរីភាព សេចក្តីថ្លៃថ្នូរ